ការដឹកជញ្ជូនផល អនុផលព្រៃឈើ ឬសន្និធិខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន ឬសន្និធិ ត្រូវចាត់ទុកជាល្មើសច្បាប់ ។

មាត្រា ៧០.-

មុនពេលបើកការដ្ឋានប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវយកគ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទដែលបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើ ទៅសុំការអនុញ្ញាតចុះបញ្ជីនិងបិទស្លាកជាសំគាល់នៅរដ្ឋបាលព្រៃឈើ ។

គ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទដែលបំរើឱ្យការប្រមូលផល អនុ-ផលព្រៃឈើដោយពុំបានចុះបញ្ជី និងបិទស្លាកជាសំគាល់របស់រដ្ឋបាលព្រៃឈើ ហើយធ្វើចរាចរក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់។

រាល់គ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទដែលព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបស្របច្បាប់មានបំណងធ្វើការនាំចូលដើម្បីបម្រើឱ្យការប្រមូលនិងដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវឆ្លងកាត់ការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ការប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើ ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

មាត្រា ៧១.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទត្រូវកំណត់ដោយប្រកាសនូវចំនួនមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ដើម្បីធានាបាននូវការផ្គត់ផ្គង់វត្ថុធាតុដើមជាផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ។

វត្ថុធាតុដើមសម្រាប់មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ត្រូវមានប្រភពពីព្រៃសម្បទាន ព្រៃគុប ឈើរំបម្លាស ឬពីប្រភពស្របច្បាប់ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៧២.-

ការនាំចេញផល អនុផលព្រៃឈើគ្រប់ប្រភេទទៅបរទេស ត្រូវសម្រេចតាមកំរិតកំណត់ប្រចាំឆ្នាំដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

យថាប្រភេទផល អនុផលព្រៃឈើដែលអនុញ្ញាតឱ្យនាំចេញ នាំចូល ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ នាំចូលផល អនុផលព្រៃឈើ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

មាត្រា ៧៣.-

អាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើ ត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន ។ ការពន្យារសុពលភាពនៃអាជ្ញាប័ណ្ណនេះត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម ។

រាល់ផល អនុផលព្រៃឈើនាំចេញដែលរៀបចំផ្ទុកក្នុងខុនថៃនណឺ ចាំបាច់ត្រូវមានការត្រួតពិនិត្យជាមុនដោយមន្ត្រីរដ្ឋបាលព្រៃឈើ និងបិទសំណភ្ជិតមុនពេលអនុញ្ញាតដឹកជញ្ជូនទៅកាន់ឃ្លាំង និងទីលានបញ្ចេញទំនិញពីគយ ។ គំរូសំណបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញនេះត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ការនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវបង់ពន្ធនាំចេញ នាំចូល និងពន្ធផ្សេងៗទៀតចូលថវិកាជាតិ ។

មាត្រា ៧៤.-

ឈើរសាត់តាមខ្សែទឹក កៀង ឬលិចដែលគ្មានដាក់សញ្ញា និងឈើគ្មានម្ចាស់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋដោយដាក់លក់ឱ្យដេញថ្លៃជាសាធារណៈ ។

ក្នុងករណីមានបុគ្គលណាមួយទាមទារថា ឈើដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ ជារបស់ខ្លួននោះ ត្រូវឱ្យបុគ្គលនោះបង្ហាញភស្តុតាងជាក់ស្តែងជាអាទិ៍ លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ លិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្និធិ ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ ចាប់ពីថ្ងៃប្រកាសជូនដំណឹងដោយរដ្ឋបាលព្រៃឈើ ។

ថ្លៃលក់ឈើ ដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ មាត្រា ៧៤ នៃច្បាប់នេះ ត្រូវបង់ចូលថវិកាជាតិ ។

ក្នុងករណីមានការបាត់បង់ឈើរសាត់តាមខ្សែទឹក កៀង ឬលិច ក៏ដូចជាការបាត់បង់ផល អនុផលព្រៃឈើផ្សេងទៀត ដែលរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចបានផ្ញើឱ្យថែរក្សាបុគ្គល ឬអាជ្ញាធរដែលទទួលថែរក្សាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

មាត្រា ៧៥.-

បុគ្គលដែលប្រមូលដឹកជញ្ជូន កែច្នៃ សន្និធិ លក់ដូរ ឬនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវទទួលខុសត្រូវ ក្នុងការបង្ហាញឯកសារដើមស្របច្បាប់នៃផល អនុផលព្រៃឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ ។

ជំពូកទី ១៤
នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

មាត្រា ៧៦.-

បទល្មើសព្រៃឈើ ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់នេះ ។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ ។

ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

មាត្រា ៧៧.-

នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ។

មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានលុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧៨.-

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយនិងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កំលាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ឬថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្តែង អាជ្ញាធរទាំងនោះ :

១- ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត ។

២- អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និងចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី ។

៣- មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ ។

មាត្រា ៧៩.-

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិ ដូចតទៅ :

១- អាចឱ្យបុគ្គលណាមួយឆ្លើយតបសំណួរនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ ។

២- ចូលធ្វើការត្រួតពិនិត្យ ឬឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ។

៣- ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិចូលឆែកឆេរនៅក្នុងទីធ្លា អាគារ ឬក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ ។ ការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់សង្ស័យនិងមានសាក្សីពីរ (២)នាក់ដែលជាអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ ។

មាត្រា ៨០.-

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន :

១- រាល់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២- សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ ។

៣- គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើនិងសត្វព្រៃ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ។

មាត្រា ៨១.-

ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ។

មាត្រា ៨២.-

វត្ថុតាងនៃបទល្មើសព្រៃឈើ ត្រូវបានកំណត់ដូចខាងក្រោម :

១- ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដ នៃបទល្មើស ។

២- សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ ខាងលើនេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្ន រហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជំរះរបស់តុលាការ ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬផលប្រមាញ់ល្មើស អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើសនិងអ្នកសមគំនិត ។

ផលប្រមាញ់ស្រស់ជាអាទិ៍ សត្វរស់ និងសំណាកសត្វព្រៃដែលបានឃាត់ទុកហើយងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិលែង ឬបំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ។

មាត្រា ៨៣.-

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ ។

មាត្រា ៨៤.-

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ ។

មាត្រា ៨៥.-

អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើមាន :

១- បទល្មើសព្រៃឈើថ្នាក់ទី ១ មានអាជ្ញាយុកាលដប់ប្រាំ (១៥)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

២- បទល្មើសព្រៃឈើថ្នាក់ទី ២ មានអាជ្ញាយុកាលប្រាំ (៥)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

៣- បទល្មើសព្រៃឈើថ្នាក់ទី ៣ មានអាជ្ញាយុកាលមួយ(១)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

ការអនុវត្តន៍អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើ ត្រូវស្របតាមនីតិវិធីព្រហ្មទណ្ឌ ។

មាត្រា ៨៦.-

បុគ្គលដែលប្រព្រឹត្តបទល្មើសព្រៃឈើដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។

បុគ្គលជាភ្នាក់ងារនៃអង្គភាពរដ្ឋ ឬឯកជនដែលប្រើប្រាស់មធ្យោបាយរបស់អង្គភាពដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ បុគ្គល ឬប្រធានអង្គភាពនោះ ត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បទល្មើសព្រៃឈើដែលប្រព្រឹត្តឡើងដោយបុគ្គលឬក្រុម ក្រោមការចាត់តាំងរបស់អង្គភាពណាមួយ ប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៨៧.-

រូបវន្តបុគ្គលបរទេស ឬនីតិបុគ្គលបរទេសដែលបានប្រព្រឹត្តបទល្មើសព្រៃឈើត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៨៨.-

មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចមានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូលឬមួយផ្នែក មួយរយៈ ដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទានិកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទានរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។

មាត្រា ៨៩.-

បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចណាមួយ ធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្របតាមច្បាប់នេះ មានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលសេចក្តីសម្រេចនេះមកប្រធានរដ្ឋបាលព្រៃឈើ។

ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃយ៉ាងយូរ ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញ

ដោយប្រធានរដ្ឋបាលព្រៃឈើ ក្នុងករណីមិនអាចទទួលយកបាន ជននោះអាចធ្វើបណ្តឹងតវ៉ាទៅតុលាការ ។

ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាចនិងដំណើរការអនុវត្តន៍ច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។

ជំពូកទី ១៥
បទល្មើសព្រៃឈើ និងទោសប្បញ្ញត្តិ

មាត្រា ៩០.-

ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមាន : ទោសជាប់ពន្ធនាគារ រឹបអូសវត្ថុតាង ពិន័យដោយតុលាការ ពិន័យអន្តរការណ៍ ការជួសជុលការខូចខាត ការព្រមាន ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ការជួសជុលការខូចខាត និងការព្រមានជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬជួសជុលការខូចខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ ។

ចំពោះមន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលកំណត់ក្នុងច្បាប់នេះ ។

មាត្រា ៩១.-

រដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើដូចមានចែងក្នុងមាត្រា ៩៦ នៃច្បាប់នេះ ។ ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើអាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ (១៥)ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។

បែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ :

១- ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស ។

២- ការខូចខាតដល់បរិស្ថាន ។

៣- ចំនួននៃការប្រព្រឹត្តល្មើស ។

៤- បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល ។

៥- ការប្រព្រឹត្តល្មើសដោយចេតនា ។

មាត្រា ៩២.-

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមតុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាង ត្រូវបង់ចូលថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសព្រៃឈើជាក់លាក់ណាមួយ ។

មាត្រា ៩៣.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំទៅដប់ (១០)ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ។

២- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ២ ត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំទៅប្រាំ (៥)ឆ្នាំ និង/ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០)រៀលទៅមួយរយលាន (១០០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៣- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ៣ ត្រូវជាប់ពន្ធនាគារពីមួយ (១)ខែទៅមួយ (១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៤- ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីអនុវត្តនីឯកភាពទូទាំងប្រទេស ។

មាត្រា ៩៤.-

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។

មាត្រា ៩៥.-

រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាន និងតម្រូវឱ្យជួសជុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម :

១- ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំការឈើ ឬថ្នាលកូនឈើរបស់រដ្ឋ ដោយបំផ្លាញឈើ ឬកូនឈើនៅទីនោះ ។

២- ធ្វើឱ្យរបួស ឬធ្វើឱ្យខូចខាតដល់ដើមឈើ ឬរុក្ខជាតិផ្សេងទៀតដែលកំពុងថែរក្សា ឬដែលបានដាំ ។

៣- លួច ឬធ្វើឱ្យខូចខាតដល់របង បង្គោល ឬស្លាកសញ្ញាក្នុងថ្នាលបណ្តុះកូនឈើ ឬក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

មាត្រា ៩៦.-

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ (២)ទៅ បី(៣)ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១- កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ ។

២- ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៣- ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៤- ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅលើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន។

៥- ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព ។

៦- មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៧- ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ។

៨- នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និងប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ ។

៩- កាប់រំលំ អារ ច្រៀក និងចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬប្រើរណារយន្តជាមធ្យោបាយ ប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសញ្ញា ។

១០- ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត ។

១១- ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១២- ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ ឬប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៣- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយបានមកពីការកាប់ ឬរុករក ដឹកជញ្ជូន កែច្នៃដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៤- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៥- នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ ។

១៦- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ។

១៧- យកធ្វើជាកម្មសិទ្ធ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយកម្រ ។

១៨- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ ។

១៩- ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយបង្គួរ ដោយគ្មានលិខិតអនុញ្ញាត ។

២០- បរបាញ់ក្នុងទីសាធារណៈ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ មិនរាប់ចាប់ក្នុងរយៈពេលមួយ (១)ខែ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ(២)ទៅបួន(៤)ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ។

វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ ត្រូវរឹបអូសជាសម្បត្តិរដ្ឋស្របតាមបទប្ប-ញ្ញត្តិនៃច្បាប់នេះ ។ វត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលព្រៃឈើ អាចប្រគល់ឱ្យសាមីជនវិញតែក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ៩៦ នៃច្បាប់នេះ។

មាត្រា ៩៧.-

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំ ទៅដប់ (១០)ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ដកហូតកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងកំទេចចោលវត្ថុតាងក្លែង ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- ក្លែងញញួរត្រា ឬប្រើញញួរត្រាក្លែង ឬបំផ្លាញស្លាមញញួរត្រារដ្ឋបាលព្រៃឈើដែលវាយលើឈើហ៊ុប ។

២- ក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ឬពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ។

៣- ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬសត្វព្រៃ។

៤- បំផ្លាញ លាក់ចាំង លក់ ឬលួចវត្ថុតាងព្រៃឈើ ។

៥- កំទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតដល់ព្រំសីមានៃតំបន់ព្រៃឈើ ។

៦- កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ។

៧- បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា ។

៨- គៀរ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬគាស់រំលើងប្រមូលគល់ឈើ ។

៩- បង្កើតមូលដ្ឋានកែច្នៃរល្លីរមៀត ឬមូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំផ្លាញព្រៃឈើនិងមជ្ឈដ្ឋានព្រៃឈើ ។

១០- បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ១ មិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសព្រៃឈើថ្នាក់ទី ១ នៃច្បាប់នេះ ។

មាត្រា ៩៨.-

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- មិនគោរពតាមបទបញ្ញាបច្ចេកទេសដែលបានកំណត់ក្នុងក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

២- មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣- យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ ។

៤- ប្រើប្រាស់គ្រឿងចក្រ យានយន្តបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសំគាល់ ។

៥- គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

៦- ប្រើប្រាស់ដីព្រៃឈើលើសពីទំហំអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាត ដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅដ្ឋានគ្រប់ប្រភេទតាមដងផ្លូវ ។

៧- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ប្រភេទធំ និងមធ្យមដោយគ្មានប្រកាស ។

៨- បង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត ។

៩- បរបាញ់ក្នុងរដូវកាលហាមឃាត់ឬក្នុងតំបន់ការពារ ។

១០- បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ ។

១១- បរបាញ់សត្វព្រៃដោយប្រើមធ្យោបាយដែលបង្កគ្រោះថ្នាក់ដល់ជីវ-សាស្ត្រសត្វ ។

១២- យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលប្រភេទសត្វរស់ និងសំណាកក្នុងក្រុមជិតផុតពូជ ។

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន(១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១- ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

២- ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬក្រៅភូមិសាស្ត្រដែលកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣- ផ្ទេរសិទ្ធិ ឬលក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤- កាប់ដើមឈើក្នុងចំការដាំឈើរបស់រដ្ឋ ។

៥- ប្រមូលផល អនុផលព្រៃឈើ ចំពោះប្រភេទឈើជាប់លំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោះយកជ័រតាមប្រពៃណីនិងប្រភេទឈើផ្តល់ជ័រមានតម្លៃ ។

៦- នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ដោយគ្មានទិដ្ឋាការពីអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ និងគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧- នាំចេញផល អនុផលព្រៃឈើដែលគ្មានអាជ្ញាប័ណ្ណ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ២ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១ នៃច្បាប់នេះ ។

មាត្រា ៩៩.-

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ៣ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ (១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០)រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ

ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១- ប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

២- នាំចូលគ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើ ដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣- នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទភ្ជិតរបស់រដ្ឋបាលព្រៃឈើលើខុនថៃនណឺ ។

៤- យាយី ធ្វើឱ្យរបួស ប្រមូលពង កូន នៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយកម្រ ឬបំផ្លាញជម្រករបស់វា ។

៥- បង្កើតរោងសន្និធិ លក់ដុំ រាយ នូវផល អនុផលព្រៃឈើនិងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ដោយគ្មានលិខិតអនុញ្ញាត ឬផ្ទុយពីការកំណត់ ។

៦- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬមិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬជាប្រភពថាមពលខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ៣ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ នៃច្បាប់នេះ ។

មាត្រា ១០០.-

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ ផ្តល់ការអនុញ្ញាតដោយផ្ទាល់ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬរាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០)រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ។

មាត្រា ១០១.-

ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល :

១- ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២- ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

៣- អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។

៤- ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬធ្វើជានិយោជិក ឬអ្នកធានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១)ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ ។

៥- មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦- ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្សណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ ។

ជំពូកទី ១៦

ការអនុវត្តន៍សាលក្រមតុលាការ

មាត្រា ១០២.-

ការអនុវត្តន៍សាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើ ជាភារកិច្ចរបស់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចលើកលែងតែទោសជាប់ពន្ធនាគារ ។

មាត្រា ១០៣.-

រាល់សម្រេចសាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

មាត្រា ១០៤.-

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលព្រៃឈើ ។

ជំពូកទី ១៧
អន្តរប្បញ្ញត្តិ

មាត្រា ១០៥.-

ព្រៃសម្បទានទាំងឡាយ ទោះជាមានស្រាប់នៅមុនពេលច្បាប់នេះចូលជាធរមានក្តី ឬបានផ្តល់ឱ្យក្រោយៗមកទៀត តាមការដាក់ឱ្យដេញថ្លៃជាសាធារណៈដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះក្តី ព្រៃសម្បទានិកត្រូវចុះកិច្ចព្រមព្រៀងព្រៃសម្បទានតាមគំរូថ្មីតែមួយជាមូលដ្ឋាន ។

មាត្រា ១០៦.-

នៅទីណាដែលរដ្ឋបាលព្រៃឈើមានភស្តុតាងបញ្ជាក់ថា ការកាន់កាប់ដីព្រៃណាមួយបានមកពីការកាប់រានដីព្រៃឈើរដ្ឋដោយខុសច្បាប់មុនច្បាប់នេះចូលជាធរមាន រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតជូនដំណឹងក្នុងនាមរាជរដ្ឋាភិបាលជាម្ចាស់កម្មសិទ្ធិលើដីព្រៃឈើរដ្ឋដោយធ្វើការបណ្តេញ និងទាមទារកម្មសិទ្ធិដីព្រៃឈើរដ្ឋមកវិញដោយឥតលក្ខខណ្ឌ ។

មាត្រា ១០៧.-

នៅពេលច្បាប់នេះចូលជាធរមាន រោងចក្រ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងឡាយដែលបានបង្កើតឡើង និងកំពុងដំណើរការក្រោមប្រកាសអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងនោះ ត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពរហូតដល់ផុតសុពលភាពនៃប្រកាស ។

ចំពោះរោងចក្រកែច្នៃផល អនុផលព្រៃឈើត្រូវបំពេញបែបបទសុំបន្តផលិតកម្មអាជីវកម្មស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ក្នុងរយៈពេលប្រាំមួយ (៦)ខែ គិតពីច្បាប់នេះចូលជាធរមាន ។

ជំពូកទី ១៨

អវសានប្បញ្ញត្តិ

មាត្រា ១០៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១០៩.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

នស.០២.០៨.០០២៧២ **ហត្ថលេខា និង ត្រា**

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

ចាន់ សារុន

លេខ: ១៨៤ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន សារី

ឧបសម្ព័ន្ធ

សន្ទានុក្រម

កិច្ចព្រមព្រៀងព្រៃសម្បទាន : កិច្ចសន្យារវាងរដ្ឋ និង ព្រៃសម្បទានិកសំរាប់ដំណើរការគ្រប់គ្រង និង ប្រមូលផល-អនុផលព្រៃឈើប្រកបដោយនិរន្តរភាពលើតំបន់ព្រៃសម្បទានដែលរដ្ឋបានផ្ដល់សិទ្ធិឱ្យប្រើប្រាស់ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបណ្ដាលក្ខខណ្ឌដែលបានព្រមព្រៀង ។

ដីសហគមន៍ជនជាតិដើមភាគតិច : ដីមានលក្ខណៈស្របច្បាប់សំរាប់ការចុះបញ្ជិកាដោយរដ្ឋជាសម្បត្តិរបស់សហគមន៍ក្រោមច្បាប់ភូមិបាល ។

ថ្លៃសួយសារ : បរិមាណប្រាក់បង់ដោយរូបវ័ន្តបុគ្គល នីតិបុគ្គល ឬ សហគមន៍ណាមួយជូនរដ្ឋសំរាប់ផល-អនុផលព្រៃឈើដែលបានធ្វើការប្រមូលផលនៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ ។

ធនធានព្រៃឈើ : ធនធានជីវសាស្ត្រទាំងឡាយដែលកំណត់លើផ្ទៃដីព្រៃឈើមួយជាក់លាក់ រួមមានធនធានរុក្ខជាតិព្រៃឈើ និង ធនធានសត្វព្រៃ គ្រប់លំដាប់ថ្នាក់ និងគ្រប់ប្រភេទរួមទាំងធនធានអជីវសាស្ត្រផ្សេងៗទៀតដែលស្ថិតនៅក្នុងនោះ ក្រៅអំពីរ៉ែក្រោមដី ។

ប្លុកប្រមូលផល : ឯកតាគ្រប់គ្រងតូចបំផុតនៅក្នុងព្រៃគុប ដែលមានមុខងារសំរាប់ត្រួតពិនិត្យលើកិច្ចដំណើរការប្រមូលផលព្រៃឈើ ។

បុព្វលាភ : ថ្លៃដែលអ្នកកាន់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាត បង់បន្ថែមលើថ្លៃសួយសារដែលជាលក្ខខណ្ឌមួយសំរាប់បំពេញការងារលើផ្ទៃដីព្រៃឈើមួយជាក់លាក់ ។

ប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ : សំណុំអន្តរអំពើចំរុះនៅលើផ្ទៃដីមួយជាក់លាក់ រវាងបណ្ដាភាវៈមានជីវិត (សារព័ន្ធរុក្ខជាតិ-សត្វ មីក្រូសរីរាង្គ) ជាមួយនឹងមជ្ឈដ្ឋានគ្មានជីវិត (អាកាសធាតុ មីក្រូអាកាសធាតុ ដី ទឹក) ដែលបង្កនូវស្ថាបនកម្មរបស់ព្រៃឈើ និងជាឯកតាបំពេញមុខងារមួយនៅលើសំបកផែនដី ។ មនុស្សរួមជាមួយតម្រូវការផ្នែកសេដ្ឋកិច្ច ប្រពៃណី វប្បធម៌ និង បរិស្ថាន ក៏ជាផ្នែកចំរុះមួយនៃបណ្ដាប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែរ ។

ផល-អនុផលព្រៃឈើ : ផលិតផលដែលផ្ដល់ដោយព្រៃឈើរួមមានផលឈើ និង ផលមិនមែនឈើព្រមទាំងផលិតផលកែច្នៃបន្ទាប់របស់វាក៏ដូចជាសេវាកម្មដែលផ្ដល់ដោយព្រៃឈើ ។

ផ្ទៃដីព្រៃសំរាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត : ផ្ទៃដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំ ដែលចំពោះមុខមិនទាន់ស្ថិតនៅក្រោមការប្រើប្រាស់ណាមួយនៅឡើយ ហើយត្រូវចាត់ក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ជាបណ្ដោះអាសន្ន ។

ព្រៃឈើ : ឯកតានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬ សិប្បនិមិត្តក្រោមទំរង់ជាដីសើម ដីលិច

ទឹក ឬ ដីសើ្ងត ដែលគ្របដណ្តប់ដោយរុក្ខជាតិចំរុះ ទោះបីដុះដោយធម្មជាតិក្តី ឬដោយដាំក្តី រួមទាំងធនធានសត្វព្រៃ និងធនធានធម្មជាតិដទៃដែលស្ថិតនៅក្នុងនោះដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺជាផល-អនុផលព្រៃឈើ ឬសេវាកម្មផ្តល់ដោយព្រៃឈើ ។ ពុំត្រូវចាត់ទុកជាព្រៃឈើតាមន័យរបស់ច្បាប់នេះ គឺដីដែលបានកំណត់ដោយរដ្ឋជាដីកសិកម្មស្ថេរ រួមមានចំការដីទំនេរសំរាប់ផលិតកម្មកសិកម្មក្រៅពីផលឈើ ដីក្នុងតំបន់ឧស្សាហកម្ម និង ដីសំរាប់នគរូបនីយកម្ម និងសំណង់ ។

ព្រៃបំរុងទុកអចិន្ត្រៃយ៍ : ព្រៃឈើរដ្ឋគ្របដណ្តប់លើដី ដែលមិនមែនជាកម្មសិទ្ធិឯកជន និង ត្រូវបានចាត់ថ្នាក់ជាព្រៃផ្តល់ផល ព្រៃការពារ និង ផ្ទៃដីព្រៃសំរាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ។

ព្រៃផ្តល់ផល : តំបន់ព្រៃដែលមានមុខងារចំបងសំរាប់ផលិតកម្មផលព្រៃឈើ ប្រកបដោយនិរន្តរភាព។ ព្រៃផ្តល់ផលរួមមាន ព្រៃសម្បទាន ព្រៃអនុញ្ញាតឱ្យធ្វើអាជីវកម្ម ព្រៃរិចរិល តំបន់ព្រៃឈើត្រូវស្តារឡើងវិញ តំបន់បំរុងទុកសំរាប់ការបន្តពូជព្រៃឈើ ឬចំការព្រៃឈើ តំបន់ដាំព្រៃឈើឡើងវិញ និងតំបន់ព្រៃឈើស្ថិតក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋាន ។

ព្រៃការពារ : តំបន់ព្រៃដែលមានមុខងារចំបងសំរាប់ការពារប្រព័ន្ធមជ្ឈដ្ឋានជាអាទិ៍ រក្សានិយតភាពប្រភពទឹក អភិរក្សជីវៈចំរុះ អភិរក្សដី ទឹក ទីជំរាល តំបន់ផ្ទៃរងទឹកភ្លៀង ជំរកសត្វព្រៃ មច្ឆជាតិ រាំងទឹកជំនន់ ការពារការហូរច្រោះ រារាំងការទន្ទ្រាននៃទឹកសមុទ្រ រក្សាជីជាតិដី ឬមានតំលៃសំរាប់សម្បត្តិវប្បធម៌ ដែលបំរើប្រយោជន៍សាធារណៈ។ ព្រៃការពារមិនបញ្ចូលនូវតំបន់ការពារធម្មជាតិក្រោមយុត្តាធិការនៃក្រសួងបរិស្ថាន អនុលោមតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រង ធនធានធម្មជាតិឡើយ ។

ព្រៃសហគមន៍ : ព្រៃរបស់រដ្ឋដែលបានប្រគល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខ័ណ្ឌរដ្ឋបាលព្រៃឈើជាមួយសហគមន៍ ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុង ឬក្បែរព្រៃដែលពឹងផ្អែកលើព្រៃឈើសំរាប់ការចិញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណី ហើយដែលបានព្រមព្រៀងធ្វើការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើនោះប្រកបដោយនិរន្តរភាព ។

ព្រៃឯកជន : ចំការឈើដែលបានដាំ ឬដើមឈើដែលដុះដោយធម្មជាតិលើដីដែលបានចុះបញ្ជិកា និង ផ្តល់ជាកម្មសិទ្ធិឯកជនក្រោមនីតិវិធី និងច្បាប់រដ្ឋ ។

ព្រៃសម្បទានិក : នីតិបុគ្គល ឬជាអង្គភាពស្របច្បាប់ជាតិ ឬបរទេស ដែលត្រូវផ្តល់សិទ្ធិប្រើប្រាស់ចំពោះព្រៃសម្បទានដោយរដ្ឋតាមរយៈដំណើរការដេញថ្លៃជាសាធារណៈស្របតាមច្បាប់នេះ ។

ព្រៃគុប : ផ្ទៃដីព្រៃឈើប្រភេទព្រៃផ្តល់ផល ដែលកំណត់ដោយភូមិសាស្ត្រជាក់លាក់ និងបង្កើតជាមូលដ្ឋាននៃ " ផ្ទៃដីប្រមូលផលព្រៃឈើប្រចាំឆ្នាំ " នីមួយៗកំណត់នៅក្នុងផែនការគ្រប់គ្រងព្រៃសម្បទាន និងផែនការប្រមូលផលប្រចាំឆ្នាំ ។

រដ្ឋបាលព្រៃឈើ : អាជ្ញាធររដ្ឋាភិបាលគ្រប់ថ្នាក់ដែលមានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើស្របតាមគោលនយោបាយព្រៃឈើជាតិ និងអនុវត្តតាមច្បាប់នេះ ។

វិស័យព្រៃឈើ : ប្រព័ន្ធនៃកិច្ចការអនុវត្តនីចំពោះព្រៃឈើ ផ្ទៃដីព្រៃឈើ និងផល-អនុផលព្រៃឈើក្រោមវិធានគ្រប់គ្រងចំរុះដែលរួមបញ្ចូលនូវគោលនយោបាយនីតិកម្ម បច្ចេកទេសវិទ្យាសាស្ត្រ និងរដ្ឋបាលព្រៃឈើ ។

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ : ព្រៃឈើទូទៅនៃព្រះរាជាណាចក្រកម្ពុជា ទោះជាកម្មសិទ្ធិរបស់ រដ្ឋ ឬឯកជន ដុះដោយធម្មជាតិ ឬដោយដាំក្តីដែលត្រូវបានកំណត់ជាពីរក្រុម៖ ព្រៃបំរុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន ហើយត្រូវរក្សាជាគំរបព្រៃឈើអចិន្ត្រៃយ៍ ដើម្បីធានាការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

សហគមន៍ : ក្រុមអ្នកស្រុករស់នៅក្នុងភូមិមួយ ឬ ច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការចាប់អារម្មណ៍រួមលើបណ្តាសង្គម វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ច ក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៃតំបន់មួយដែលពួកគាត់រស់នៅក្នុង ឬក្បែរតំបន់នោះក្នុងពេលចំណាយចិញ្ចឹមជីវិត និង កែលំអជីវភាពរស់នៅ ។

សហគមន៍មូលដ្ឋាន : សហគមន៍ជនជាតិដើមភាគតិច ឬក្រុមអ្នកស្រុកដែលមានលំនៅដើមកំណើតក្នុងភូមិមួយ ឬច្រើនស្ថិតនៅក្នុង ឬក្បែរតំបន់ព្រៃឈើរដ្ឋដែលមានប្រពៃណីទំនៀមទំលាប់ ជំនឿសាសនា វប្បធម៌ និងរស់នៅចិញ្ចឹមជីវិតដោយពឹងអាស្រ័យទៅលើការរុករកផល-អនុផលព្រៃឈើ និងប្រើប្រាស់ធនធានព្រៃឈើទាំងនោះជាមូលដ្ឋាន ។

សហគមន៍ព្រៃឈើ : សហគមន៍ដែលស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំក្រោមកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ដើម្បីធ្វើសកម្មភាព អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ។

អនុផលព្រៃឈើ : ផលិតផលមិនមែនជាឈើហ៊ុបដែលទាញចេញពីព្រៃឈើ រួមមាន ផលិតផលនៃរុក្ខជាតិមិនមែនឈើ ផលប្រមាញ់នៃសត្វព្រៃ និងសេវាកម្មដែលផ្តល់ដោយព្រៃឈើ ហើយដែលកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ព្រះរាជក្រឹត្យ

នស / រកត / ០៩០២ / ៧៦០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឡឹង តូម៉ាស** (LEONG TOMAS) ដើមកំណើតចិន សញ្ជាតិព័រទុយហ្គាល់ កើតថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៥៣ នៅក្រុងម៉ាកាវ ប្រទេសចិន ។

មាត្រា ២: នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខ: ១៥៩ ចល **ហត្ថលេខា និង ត្រា**

៣៤-០៧.០៩.០០៦៧៥

ដើម្បីចម្លងចែក **ជា ស៊ីម**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០២

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ិន ស៊ី

ព្រះរាជក្រឹត្យ

នស / រកត / ០៩០២/ ២៦១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **លី ធណ្ណថេង** ជាទីប្រឹក្សាកិត្តិយសរបស់ឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃព្រឹទ្ធសភា ទទួលបន្ទុកការងារសង្គមកិច្ច និងសុខាភិបាល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០២

ឡាយព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និង ត្រា

ជា ស៊ីម

លេខ : ១៤៤ ច ព

ដើម្បីចម្លងចែក

៣/ស.៦៧.០៧-០៦៤៧

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០២

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ិន ស៊ី

ព្រះរាជក្រឹត្យ

នស/រកត/០៩០២/២៦៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លឹង ហោហ្វា** (LEUNG FOR WA) សញ្ជាតិដើមចិន កើតថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៦២ នៅក្រុងហុងកុង ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និង ត្រា

ជា ស៊ីម

៣ក.ល.០២.០៩.០២២៧៨ លេខ : ៦៩០ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០២

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន សារី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

បែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការ ប្រកបវិជ្ជាជីវឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០០២

សំរេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់បែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាត ឱ្យជនបរទេសដែលជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

អាចអនុញ្ញាតឱ្យជនបរទេសដែលជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជាបាន លើកលែងតែបើក ឬប្រកបវិជ្ជាជីវៈជាទ្រង់ទ្រាយ បន្ទប់ពិគ្រោះព្យាបាលជំងឺ។ ជនបរទេសទាំងនោះ ត្រូវមានលក្ខណសម្បត្តិ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូច ខាងក្រោមនេះ:

១. មកពីបណ្តាប្រទេសដែលជាសមាជិករបស់អង្គការសុខភាពពិភពលោក

២. មានបទពិសោធន៍ក្នុងវិជ្ជាជីវសុខាភិបាលយ៉ាងតិច៥ឆ្នាំ

៣. មានចុះឈ្មោះដែលនៅមានសុពលភាពនៅឡើយ ក្នុងបញ្ជីសមាជិកគណៈវិជ្ជាជីវសុខាភិបាលនៃប្រទេសសាមី ឬ ត្រូវបានក្រសួងសុខាភិបាល-ស្ថានទូតប្រទេសសាមីទទួលស្គាល់

៤. មានសញ្ញាប័ត្រជំនាញឯកទេសខ្ពស់ ទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ចនៃប្រទេសនោះ

៥. មានកាយសម្បទា និងសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន

៦. ត្រូវគោរពទំនៀមទម្លាប់ប្រពៃណីខ្មែរ

៧. ត្រូវបានចុះឈ្មោះបន្ថែមក្នុងបញ្ជីគណៈវិជ្ជាជីវសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

៨. មិនដែលត្រូវបានផ្តន្ទាទោសជាមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទរដ្ឋបាល ដូចជាការលុបឈ្មោះចោល ឬការបញ្ឈប់ពីមុខងារ ការដកហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួន ដែលបានប្រកាសដោយតុលាការ ។

ក្រសួងសុខាភិបាលមានឆន្ទានុសិទ្ធិក្នុងការមិនអនុញ្ញាតឱ្យជនបរទេសដែលជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាអ្នកនោះឬអ្នកទាំងអស់នោះបានបំពេញ និងបានគោរពទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះក៏ដោយ ។

ជំពូកទី២
បែបបទរដ្ឋបាល

មាត្រា ៣.-

ជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលមានបំណងប្រកបវិជ្ជាជីវឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យសុំមកក្រសួងសុខាភិបាល មានសំណុំលិខិតដូចខាងក្រោមនេះ :

១. លិខិតឆ្លងដែនត្រឹមត្រូវ ដែលមានទិដ្ឋាការប្រភេទអ៊ី(E) មានសុពលភាព សមស្របទៅនឹងរយៈពេលនៃការអនុវត្តការងារ

២. ជីវប្រវត្តិសង្ខេប

៣. មានប័ណ្ណការងារ និងសៀវភៅការងារ ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យការងារ ស្របតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចសន្យាការងារដែលមានថេរៈវេលាកំណត់ជាលាយល័ក្ខណ៍អក្សរជាភាសាខ្មែរ បារាំង ឬអង់គ្លេស ។

៤. លិខិតថ្កោលទោសចេញដោយក្រសួងមានសមត្ថកិច្ចរបស់ប្រទេសសាមី ជាច្បាប់ដើម ដោយមានទិឡានុកូលកម្មត្រឹមត្រូវ ពីអាជ្ញាធរពាក់ព័ន្ធរបស់ប្រទេសសាមី និងបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៥. និងបណ្ណាឯកសារដែលបានបំពេញតាមល័ក្ខខ័ណ្ឌដែលចែងក្នុងមាត្រា២ខាងលើនេះ ។

ជំពូកទី ៣
ល័ក្ខខ័ណ្ឌនៃការប្រកបវិជ្ជាជីវៈ

មាត្រា ៤.-

ជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ កំពុងបំពេញបេសកកម្មស្របច្បាប់នៅតាមមន្ទីរពេទ្យសាធារណៈ ឬនៅមន្ទីរពេទ្យអង្គការនានា និង បម្រើឱ្យអង្គការអន្តរជាតិ អង្គការ ក្រៅរដ្ឋាភិបាល គ្មានសិទ្ធិប្រកបវិជ្ជាជីវឯកជន នៅព្រះរាជាណាចក្រកម្ពុជាទេ ។

មាត្រា ៥.-

ជនបរទេសដែលប្រកបវិជ្ជាជីវៈ នៅក្នុងមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល និងមន្ទីរសម្ភពឯកជនត្រូវអនុវត្តទៅតាមប្រកាសរបស់ក្រសួងសុខាភិបាល ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសក្នុងការសុំ បើក ឬ បិទ សុំកែទ្រង់ទ្រាយ ប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ។

សេវាកម្មនេះ អាចឱ្យប្រើប្រាស់បុគ្គលិកជាជនបរទេស សមស្របតាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យការងារនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦.-

មិនអនុញ្ញាតឱ្យ ម្ចាស់សេវាមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរសម្ភព ផ្ទេរការងារបុគ្គលិកជាជនបរទេស ដែលបម្រើការងារក្នុងមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរសម្ភព របស់ខ្លួនទៅឱ្យជនបរទេសណាមួយទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

មាត្រា ៧.-

ជនបរទេសដែលជាម្ចាស់សេវា ត្រូវមានវត្តមានក្នុងសេវារបស់ខ្លួន ក្នុងករណីអវត្តមានលើសពីដប់ថ្ងៃ (១០ថ្ងៃ) ម្ចាស់សេវា ត្រូវជូនពត៌មានមកក្រសួងសុខាភិបាល ។

ជំពូកទី ៤
ការវិនិយោគមន្ទីរពហុព្យាបាលខ្នាតអន្តរជាតិ

មាត្រា ៨.-

ការវិនិយោគមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរព្យាបាលខ្នាតអន្តរជាតិ ត្រូវគោរព តាមច្បាប់វិនិយោគ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩.-

អ្នកវិនិយោគត្រូវបំពេញតាមល័ក្ខខ័ណ្ឌស្តង់ដារវេជ្ជសាស្ត្រ កំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា ១០.-

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលបានបំពេញលក្ខណសម្បត្តិ និងល័ក្ខខ័ណ្ឌដូចមានចែងក្នុងជំពូកទី១ ទី២ ទី៣ នៃអនុក្រឹត្យនេះ។

មាត្រា ១១.-

អ្នកវិនិយោគមានកាតព្វកិច្ច ធ្វើការបណ្តុះបណ្តាលជាប្រចាំ និង សមស្របជូននិយោជិតខ្មែរតាមកម្មវិធីរបស់ក្រសួងសុខាភិបាល ។

មាត្រា ១២.-

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវដាក់ពាក្យសុំមកក្រសួងសុខាភិបាល ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ។

មាត្រា ១៣.-

ក្នុងករណីអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់ទាំងឡាយនៃអនុក្រឹត្យនេះ ក្រសួងសុខាភិបាលមានសិទ្ធិផ្អាកសកម្មភាពវិនិយោគជាបណ្តោះអាសន្ន និងកសាងសំណុំបែបបទទៅតុលាការ ។

ជំពូកទី ៥
អវសានបញ្ញត្តិ

មាត្រា ១៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតក្រុមហ៊ុនជលផល ជាសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ក្រច ចុះថ្ងៃទី ៩ ខែមីនា ឆ្នាំ ១៩៨៧ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ៩ ខែឧសភា ឆ្នាំ ១៩៨៩ ស្តីពីការជួលដែននេសាទទឹកសាប និង សមុទ្រឱ្យធ្វើអាជីវកម្ម
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានរំលាយបញ្ចូលក្រុមហ៊ុនជលផល និងអង្គភាពនេសាទរដ្ឋបឹងទន្លេសាប បង្កើតជាសហគ្រាសសាធារណៈ ដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋឈ្មោះ **ក្រុមហ៊ុនជលផល** សរសេរកាត់ថា " **ក.ហ.ជ.ផ.**" ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក.ហ.ជ.ផ. មានទីស្នាក់ការនៅក្នុងបរិវេណនាយកដ្ឋានជលផល ដីឡូត៍លេខ ១៨៦ កាច់ជ្រុងមហាវិថីព្រះនរោត្តម និង ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ក.ហ.ជ.ផ. គឺជានីតិបុគ្គលមានស្វ័យភាពផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

ក.ហ.ជ.ផ. ត្រូវស្ថិតនៅក្រោមឥទ្ធិពល នៃបទប្បញ្ញត្តិរបស់អនុក្រឹត្យនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈ ទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២.-

ក.ហ.ជ.ផ. ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុ

15

របស់ខ្លួន ។

ក.ហ.ជ.ផ. មានគោលដៅ និងភារកិច្ចដូចខាងក្រោម :

១-ទិញ លក់ទំនិញជលផលក្នុងប្រទេស និង នាំចេញ នាំចូលទំនិញជលផល និងឧបករណ៍សម្ភារៈនេសាទ

២-មានសិទ្ធិចុះកិច្ចសន្យាធ្វើពាណិជ្ជកម្ម អាជីវកម្ម ផលិតកម្ម និងសេវាកម្មទំនិញជលផល ជាមួយបណ្ដា ក្រុមហ៊ុនក្នុង និងក្រៅប្រទេស

៣-មានសិទ្ធិធ្វើអាជីវកម្មនេសាទសមុទ្រ និងចូលដេញថ្លៃធ្វើអាជីវកម្មឡូត៍នេសាទ

៤-បើកស្នាក់ការប្រមូលទិញ លក់ រាល់បណ្ដាមុខទំនិញជលផល និង ឧបករណ៍សម្ភារៈនេសាទតាមបណ្ដាខេត្ត ក្រុង

៥-គ្រប់គ្រង និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពខ្ពស់នូវធនធាន និង មធ្យោបាយផលិតកម្មអាជីវកម្ម ដែលមានស្រាប់ព្រមទាំងបំពាក់សម្ភារៈបច្ចេកទេសទំនើបៗ សម្រាប់ធ្វើការកែច្នៃផលិតផលជលផល ទៅតាមស្តង់ដារអន្តរជាតិ

៦-សិក្សាវំពីតម្លៃ និងតម្រូវការផលិតផលជលផលនៅតាមទីផ្សារក្នុង និងក្រៅប្រទេស ។

មាត្រា ៣.-

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ **ក.ហ.ជ.ផ.** ត្រូវគោរពរបបពន្ធនិងអាករ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៤.-

ដើមទុនដំបូងនៃ **ក.ហ.ជ.ផ.** ត្រូវកំណត់ឡើងតាមរយៈការផ្ទេរទុនសរុប នៃបញ្ជីតុល្យការចុងការិយ-បរិច្ឆេទ របស់អង្គភាពទាំងពីរមានក្រុមហ៊ុនជលផល និងអង្គភាពនេសាទរដ្ឋបឹងទន្លេសាប ។

អង្គភាពនេសាទរដ្ឋបឹងទន្លេសាប ត្រូវរំលាយបញ្ចូលជាមួយក្រុមហ៊ុនជលផលជាស្វ័យប្រវត្តិ នៅពេលដែលអនុក្រឹត្យនេះចូលជាធរមាន ។ រដ្ឋប្រគល់ឡូត៍នេសាទលេខ ២ ខេត្តកំពង់ធំជាដើមទុន សម្រាប់ធ្វើអាជីវកម្មជលផល ។

ចំណូលនៃឡូត៍នេសាទនេះ ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ ដោយយោងទៅលើតម្លៃឡូត៍នេសាទនៅជុំវិញនោះ ។

មាត្រា ៥.-

បុគ្គលិករបស់ **ក.ហ.ខ.ផ.** ត្រូវជ្រើសរើសពីចំណោមមន្ត្រីរាជការនៃមុខងារសាធារណៈ ដែលមានស្រាប់របស់អង្គភាពទាំងពីរ ក្នុងដំណាក់កាលផ្ទេរតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាចជ្រើសរើសបុគ្គលិកខាងក្រៅនិងបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ ។ បុគ្គលិករបស់ **ក.ហ.ខ.ផ.** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយមិនស្ថិតក្នុងក្របខ័ណ្ឌរបស់រដ្ឋតទៅទៀតទេ ។

ជំពូកទី២

ការដឹកនាំ និង ការគ្រប់គ្រង

មាត្រា ៦.-

ក.ហ.ខ.ផ. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិពេញលេញដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ បទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

- ប្រធានអគ្គនាយក **ក.ហ.ខ.ផ.** ០១ រូប ជាប្រធាន
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០១ រូប ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប ជាសមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប ជាសមាជិក
- តំណាងនិយោជិតរបស់ **ក.ហ.ខ.ផ.** ០១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៧.-

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលសកម្មធ្លាប់បានបម្រើការងារយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យបច្ចេកទេសសេដ្ឋកិច្ច វិទ្យាសាស្ត្រ ពាណិជ្ជសាស្ត្រ ឬនីតិសាស្ត្រ និង ជំនាញសមមូលផ្សេងទៀតដែលមានសញ្ជាតិខ្មែរ និងមិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈិម ពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទម្លាប់កិត្តិយស និង ភាពសុចរិត ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យ សម្រាប់អាណត្តិ ០៣ ឆ្នាំ។ អាណត្តិនេះអាច

បញ្ចប់ និងអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **ក.ហ.ខ.ផ.** ។

មាត្រា ៨.-

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសម្រេចក្នុងនាមនៃ **ក.ហ.ខ.ផ.** ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់ **ក.ហ.ខ.ផ.** ស្របតាមច្បាប់ជាធរមាន ។

ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :

១-ផ្តល់ការយល់ព្រមលើគម្រោងផែនការរបស់ **ក.ហ.ខ.ផ.**ដូចមានចែងក្នុងមាត្រា ១៦នៃអនុក្រឹត្យនេះ

២-វាយតម្លៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុកព្រមទាំងចាត់វិធានការដើម្បីកែសម្រួលឱ្យបានសមស្របតាមសភាពការណ៍

៣-ផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ក.ហ.ខ.ផ.**

៤-សម្រេចលើសំណើរបស់ប្រធានអគ្គនាយក នូវរចនាសម្ព័ន្ធនិងបទបញ្ជាផ្ទៃក្នុងរបស់ **ក.ហ.ខ.ផ.** ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សម្រាប់បុគ្គលិកដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន

៥-ផ្តល់ការយល់ព្រមលើកិច្ចសន្យានិងអនុសញ្ញាដែល **ក.ហ.ខ.ផ.** ជាភាគីហត្ថលេខីស្របតាមល័ក្ខខ័ណ្ឌនិងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន

៦-សម្រេចបង្កើត បើក ឬបិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ **ក.ហ.ខ.ផ.**តាមការវិនិច្ឆ័យរបស់ខ្លួន

៧-កំណត់ថ្លៃទិញ លក់មុខទំនិញដែលស្ថិតនៅក្នុងពាណិជ្ជកម្ម ផលិតកម្ម អាជីវកម្ម និង សេវាកម្មរបស់ **ក.ហ.ខ.ផ.**

៨-ផ្តល់ការយល់ព្រមលើសំណើទិញ ផ្លាស់ប្តូរ ឬលក់ចលនទ្រព្យ និង អចលនទ្រព្យ ព្រមទាំងរាល់សំណើខ្ចីដោយមានវត្ថុបញ្ចាំ ឬ ការធានាផ្សេងៗលើទ្រព្យសម្បត្តិរបស់សហគ្រាស ។

មាត្រា ៩.-

ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃ **ក.ហ.ខ.ផ.** តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកចំនួនបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជា

យ៉ាងណា ក៏ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេល៣ខែ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមាន ដើម្បីដឹកនាំអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌរបស់ខ្លួន។ របៀបវារៈនៃការប្រជុំព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច ១០ ថ្ងៃមុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រា តែមានវត្តមានសមាជិកយ៉ាងតិចបីនាក់ រួមទាំងប្រធានផង។

បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល។

កិច្ចប្រជុំលើកក្រោយនេះពុំចាំបាច់ទាមទារកូរ៉ុមទេ ។ សេចក្ដីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១០.-

សេចក្ដីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចម្លងចូលបញ្ជីដែលមានលេខរៀង ទំព័រជាប្រូវហែ និងមានអត្តលេខចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើមត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និង សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលមានវត្តមាន និងលេខាធិការជ្រើសរើស ដោយប្រធានអគ្គនាយក **ក.ហ.ជ.ផ.** ។

មាត្រា ១១.-

ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារប្រក្រតីនៃ **ក.ហ.ជ.ផ.** និងត្រូវតែងតាំងសម្រាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ តំណែងនេះអាចបញ្ចប់ និងអាចបន្តទៀតបាន ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ១២.-

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ជូនប្រធានអគ្គនាយកនូវអំណាចចាំបាច់ទាំងឡាយ សម្រាប់ដំណើរការ ប្រចាំថ្ងៃដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ ។

Ministry of Economy and Finance
Ministry of Industry, Mines and Energy
Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
Royal Cambodian Embassy in Paris
Royal Cambodian Embassy in Washington DC
US Embassy in Phnom Penh
EU Delegation in Bangkok
EU Delegation in Phnom Penh
Garment manufacturers Association in Cambodia
MOC Archives

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
****

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និង យុវនីតិសម្បទា

លេខ :៤៤៣ សកបយ

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០០២

ប្រកាស
ស្តីពី
ការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់តាវការលិក និង អត្រាបាត់បង់សមត្ថភាពការងារ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស /៩៤ចុះថ្ងៃ ទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/ ០១ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

សំរេច

ប្រការ ១.-

នាយក ឬ ម្ចាស់សហគ្រាស និងគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម

កសិកម្ម សេវាកម្ម សហគ្រាសដឹកជញ្ជូនតាមផ្លូវគោកឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនាឬក្នុងសាសនា ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬ ជាការកុសល ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬ ក្រុមហ៊ុនប្រភេទណាក៏ដោយត្រូវប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីគ្រោះថ្នាក់ការងារដែលបានធ្លាក់លើរូបកាយកម្មករ និយោជិតរបស់ខ្លួន។

ការប្រកាសជូនដំណឹងនេះ ត្រូវផ្ញើទៅនាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ប្រសិនបើ សហគ្រាសនោះមានទីតាំង នៅក្នុងទីក្រុងភ្នំពេញ។ ចំពោះសហគ្រាស ដែលមានទីតាំងនៅក្នុងខេត្តក្រុងដទៃផ្សេងទៀតនិយោជក ឬម្ចាស់សហគ្រាសនោះ ត្រូវប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ ទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានៃខេត្ត ឬ ក្រុង ដែលសហគ្រាសនោះតាំងនៅ ។

ប្រការ ២.-

ការប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារត្រូវផ្ញើតាមសំបុត្រអនុសិដ្ឋ ឬ សំបុត្រជូនផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលហើយ ក្នុងរយៈពេលយ៉ាងយូរបំផុតសែសិបប្រាំបីម៉ោងបន្ទាប់ពីពេលមានគ្រោះថ្នាក់ ដោយមិនគិតថ្ងៃឈប់សំរាក ឬថ្ងៃបុណ្យ។

គំរូនៃសេចក្តីជូនដំណឹងអំពីគ្រោះថ្នាក់ការងារមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ នៃប្រកាសនេះ។

ប្រការ ៣.-

កម្មករនិយោជិតដែលបានរងគ្រោះថ្នាក់ការងារ ក៏ត្រូវមានកាតព្វកិច្ចជូនដំណឹងដល់និយោជក ឬអ្នកតំណាងពេញច្បាប់របស់និយោជកអំពីគ្រោះថ្នាក់ការងារដែលបានធ្លាក់មកលើខ្លួនក្នុងរយៈពេលយ៉ាងយូរបំផុតម្ភៃបួនម៉ោងបន្ទាប់ពីឧប្បត្តិហេតុកើតឡើង។ ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចនេះអាចលើកលែងបានក្នុងករណីប្រធានសក្តិ ឬករណីដែលខ្លួនខ្វះលទ្ធភាពទាំងស្រុងដើម្បីធ្វើការជូនដំណឹងឬក៏ការមានមូលហេតុសមហេតុសមផលណាមួយផ្សេងទៀត។

ការជូនដំណឹង ដែលតំណាងកម្មករនិយោជិត ប្រធានក្រុម និងកម្មករនិយោជិត ផ្ញើជូនទៅនិយោជកឬអ្នកតំណាងនិយោជករបស់ខ្លួននោះ ត្រូវចម្លងជូននាយកដ្ឋានសន្តិសុខសង្គម ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ក្រុងផង។

ក្នុងករណីដែលមិនអាចជូនដំណឹងដោយផ្ទាល់នៅនឹងកន្លែងកើតហេតុ ដូចជាក្នុងករណីគ្រោះថ្នាក់នៅពេលធ្វើដំណើរ ដែលច្បាប់បានកំណត់ថាជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលបំពេញបេសកកម្មទាំងក្នុងឬក្រៅប្រទេសជាដើម សេចក្តីជូនដំណឹងនេះអាចធ្វើបានតាមរយៈសំបុត្រអនុសិដ្ឋ។

ប្រការ ៤.-

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការ

ទោះដោយ ហេតុយ៉ាងណាក៏ដោយ ហើយទោះបីមានកំហុសមកពីកម្មករនិយោជិតឬគ្មានក៏ដោយ គឺ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬ ធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ ។

ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬពីកន្លែងធ្វើការ ទៅកន្លែងបើកប្រាក់ឈ្នួល ឬវិលមកវិញដោយគ្មានឈប់ ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ ។

ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានកំណត់ក្នុងច្បាប់ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ។

ប្រការ ៥.-

នៅពេលមានគ្រោះថ្នាក់ការងារកើតឡើង និយោជកឬម្ចាស់សហគ្រាស នាយកដ្ឋានសន្តិសុខសង្គម មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាខេត្ត ក្រុង ត្រូវមានភារកិច្ច ចំពោះមុខដូចតទៅ ÷

ក. ចំពោះនិយោជក ឬម្ចាស់សហគ្រាស÷

- ចាត់ឱ្យមានការសង្គ្រោះជាបន្ទាន់ដល់ជនរងគ្រោះតាមគ្រប់មធ្យោបាយ
- ជូនដំណឹងទៅក្រសួងមានសមត្ថកិច្ច
- រក្សាលក្ខណៈដើមនៃទីកន្លែងកើតហេតុ " ចំពោះគ្រោះថ្នាក់ធ្ងន់ ឬគ្រោះថ្នាក់បណ្តាលឱ្យស្លាប់ មនុស្ស "
- ក្នុងករណីតម្រូវឱ្យមានការផ្លាស់ប្តូរសភាពដើមនៃកន្លែងគ្រោះថ្នាក់ដោយសារការសង្គ្រោះត្រូវ ធ្វើកំណត់ហេតុ និង ថតទុកជាឯកសារ
- ផ្តល់ឯកសារដែលពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ដល់គណៈកម្មការអង្កេត
- បង្កលក្ខណៈងាយស្រួលដល់ជនដែលបានដឹងអំពីហេតុការណ៍គ្រោះថ្នាក់ ដើម្បីជនទាំង នោះអាចរាយការណ៍ជូនគណៈកម្មការអង្កេតបាន
- ធានារ៉ាប់រងគ្រប់ការចំណាយទាំងអស់នៃការអង្កេត ចំពោះតែការវិភាគបច្ចេកទេស
- អនុវត្តឱ្យបានត្រឹមត្រូវ នូវវិធានការដែលបានចុះនៅក្នុងកំណត់ហេតុ ។

ខ. ចំពោះនាយកដ្ឋានសន្តិសុខសង្គម÷

- ជូនដំណឹងជាបន្ទាន់ទៅនាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានអធិការកិច្ចការងារដើម្បីស្នើ សុំមន្ត្រីមានសមត្ថភាព សំរាប់ចូលរួមក្នុងការអង្កេតគ្រោះថ្នាក់
- ចាត់ចែងចុះពិនិត្យ អង្កេតដល់កន្លែងកើតហេតុផ្ទាល់ឱ្យបានឆាប់បំផុត ដែលអាចធ្វើបាន
- ស្នើសុំជំនួយពីអ្នកឯកទេសជំនាញ ក្នុងករណីគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងលក្ខខណ្ឌ

បច្ចេកទេសស្មុគស្មាញ។

គ. ចំពោះមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត ក្រុង÷

- ចាត់ចែងចុះពិនិត្យ និងធ្វើអង្កេតដល់កន្លែងកើតហេតុផ្ទាល់ឱ្យបានឆាប់បំផុត ដែលអាចធ្វើបាន
- ស្នើសុំជំនួយពីអ្នកឯកទេសជំនាញ ក្នុងករណីគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងលក្ខខណ្ឌបច្ចេកទេសស្មុគស្មាញ
- ក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ ឬដល់ស្លាប់ត្រូវជូនដំណឹងជាបន្ទាន់មកនាយកដ្ឋានសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុតចិតសិបពីរម៉ោង បន្ទាប់ពីបានទទួលដំណឹងពីសហគ្រាសដែលមានឧប្បត្តិហេតុ។

រាល់ពេលចុះអង្កេតគ្រោះថ្នាក់ការងារ ត្រូវធ្វើកំណត់ហេតុបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ថាតើគ្រោះថ្នាក់នោះពិតជាគ្រោះថ្នាក់ការងារឬទេ មូលហេតុនៃគ្រោះថ្នាក់ និងត្រូវកំណត់វិធីសាស្ត្រសំរាប់បង្ការគ្រោះថ្នាក់ដដែលនេះកុំឱ្យកើតមានជាថ្មី ។ កំណត់ហេតុគ្រោះថ្នាក់ការងារ ត្រូវធ្វើតាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធ ២ នៃ ប្រកាសនេះ។

របាយការណ៍ប្រចាំ ឆមាស និងប្រចាំឆ្នាំអំពីគ្រោះថ្នាក់ការងារ ត្រូវធ្វើតាមតារាងគំរូដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ ៣ និង ៤ នៃប្រកាសនេះ ។

ប្រការ ៦.-

ក្នុងពេលដែលបេឡាជាតិសន្តិសុខសង្គមមិនទាន់បង្កើត និយោជក ឬម្ចាស់សហគ្រាសដូចមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចផ្តល់តាវកាលិកសំរាប់ជួសជុលគ្រោះថ្នាក់ការងារបន្ថែមលើសោហ៊ុយ សំរាប់ជួយសង្គ្រោះគ្រាដំបូង ។ តាវកាលិកសំរាប់ជួសជុលគ្រោះថ្នាក់ការងារមានជាអាទិ៍ ដូចតទៅ÷

-ការជួយឧបត្ថម្ភសំរាប់ការព្យាបាល និងថែរក្សាជំងឺ

-ប្រាក់បំណាច់ប្រចាំថ្ងៃ

-ធនលាភ

-សោហ៊ុយសំរាប់បូជាសព និងធនលាភសំរាប់អ្នកនៅក្នុងបន្ទុករបស់អ្នករងគ្រោះ ។

ចំពោះគ្រោះថ្នាក់ចរាចរ ដែលមានលក្ខណៈជាគ្រោះថ្នាក់ការងារ ការជួសជុលដែលចេញឱ្យដោយភាគីទីបី ពោលគឺភាគីដែលបង្កឱ្យមានគ្រោះថ្នាក់ ក៏ត្រូវចាត់ទុកជាតាវកាលិកគ្រោះថ្នាក់ការងារដែរ។ និយោជកមានសិទ្ធិប្តឹងទាមទារឱ្យភាគីទីបីចេញតាវកាលិកគ្រោះថ្នាក់ប្រភេទនេះមកឱ្យខ្លួន ប្រសិនបើតាវកាលិកនេះសហគ្រាស បានសងទៅអ្នករងគ្រោះរួចហើយ។ ទោះជាមានចែងដូច្នេះក្តី តាវកាលិកផ្នែកនេះ ត្រូវតែស្ថិតនៅក្នុងបន្ទុកនិយោជកជាអ្នកទទួលរ៉ាប់រង ពោលគឺនិយោជកត្រូវរ៉ាប់រងរាល់

ការចំណាយទាំងអស់ជាមុនសិន រួចទើបដោះស្រាយជាមួយភាគីទីបី ជាក្រោយ។

អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ មានបុព្វសិទ្ធិពេញលេញក្នុងការទាមទារតាវកាលិករបស់ខ្លួន ក្នុងករណីដែលតុលាការចេញសាលក្រមបញ្ជាក់ថាសហគ្រាសក្ស័យធន។

ប្រការ ៧.-

ការជួយឧបត្ថម្ភសំរាប់ការព្យាបាល និងថែរក្សាអ្នករងគ្រោះក្នុងរយៈពេលសំរាកព្យាបាលនៅមន្ទីរពេទ្យរាប់ទាំងការព្យាបាលពេលរបួស ឬជំងឺរើឡើងវិញ និងការជួយឧបត្ថម្ភផ្សេងៗបន្ទាប់ពីមុខរបួសបានជាសះស្បើយ គឺជាកាតព្វកិច្ចរបស់និយោជកចំពោះជនរងគ្រោះថ្នាក់ការងារ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាកាលិក ឬបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយផ្នែក ឬទាំងស្រុង បន្ទាប់ពីមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យ ផ្លូវការដែលមានការយល់ព្រមពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ តាវកាលិកផ្នែកនេះមានកំណត់ដូចតទៅ៖

- ប្រាក់ចំណាច់សំរាប់ការព្យាបាល ការព្យាបាលដោយវះកាត់ ការព្យាបាលខាងទន្តសាស្ត្រ ការពិនិត្យដោយវិទ្យុកាំរស្មីអ៊ិចឬអេកូសាស្ត្រ ការពិនិត្យនៃមន្ទីរពិសោធន៍ និងរាល់ការវិភាគផ្សេងៗដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យមាន
- ប្រាក់ចំណាយសំរាប់ទិញឱសថ និងគ្រឿងប្រើប្រាស់បន្ទាប់បន្សំទាក់ទងនឹងការព្យាបាល ប្រាក់ឧបត្ថម្ភសំរាប់អ្នកចាំថែរក្សាជំងឺនៅក្នុងមន្ទីរព្យាបាល ឬទីផ្សេងទៀតដែលមានលក្ខណៈជាកន្លែងសំរាប់ព្យាបាល
- ការផ្គត់ផ្គង់ ការជួសជុលឬកែកុនជាថ្មីនូវអវៈយវៈសិប្បនិម្មិត ឈើច្រត់ រទេះសំរាប់មនុស្សពិការ
- សោហ៊ុយសំរាប់ដឹកអ្នករងគ្រោះពីកន្លែងគ្រោះថ្នាក់ទៅមន្ទីរពេទ្យ ឬទៅកាន់លំនៅស្ថាន
- ការឧបត្ថម្ភសំរាប់ការងារសំរបសំរួលមុខងារឡើងវិញឬការជួយបង្រៀនវិជ្ជាជីវៈអោយបានសមស្របតាម កាយសម្បទារបស់ជនរងគ្រោះ ។

ទោះបីមានការកំណត់ដូចខាងលើក្តី ក៏អ្នករងគ្រោះ អាចនឹងមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ប្រសើរជាងនេះថែមទៀត។

ប្រការ ៨.-

ក្នុងករណីគ្រោះថ្នាក់ការងារដែលបណ្តាលអោយបាត់បង់សមត្ថភាពការងារជាកាលិកឬជាអចិន្ត្រៃយ៍ដែលមានអត្រាតិចជាងម្ភៃភាគរយ ហើយមិនទាន់អាចចូលធ្វើការបាន ពោលគឺគ្រោះថ្នាក់ដែលបណ្តាលអោយ អាក់ខានធ្វើការមួយរយៈពេល ក្រៅពីអត្ថប្រយោជន៍ដូចមានចែងក្នុងប្រការ ៧ អ្នករងគ្រោះត្រូវមានសិទ្ធិទទួល នូវប្រាក់ចំណាច់ប្រចាំថ្ងៃដែលនិយោជក ត្រូវបើកឱ្យចាប់ពីថ្ងៃទីប្រាំ

នៃថ្ងៃដែលមានគ្រោះថ្នាក់នេះទៅ រហូតដល់ជាសះស្បើយ ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យផ្លូវការ ដែលទទួលស្គាល់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវស្មើនឹងប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់អ្នករងគ្រោះ។

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែករវាងប្រាក់ឈ្នួលមូលដ្ឋានរបស់អ្នករងគ្រោះនិងចំនួនថ្ងៃធ្វើការនៃអ្នករងគ្រោះ ។

ប្រាក់ឈ្នួលមូលដ្ឋាន គឺជាផលបូកនៃប្រាក់ឈ្នួលសុទ្ធសាធជាមួយអត្ថប្រយោជន៍ផ្សេងៗ ដូចជា ប្រាក់ម៉ោងបន្ថែម ប្រាក់ភារកិច្ច និងប្រាក់បំណាច់មួយចំនួនដែលមានលក្ខណៈ ជាសោហ៊ុយដូចជាសោហ៊ុយធ្វើដំណើរ សោហ៊ុយវិជ្ជាជីវៈ សោហ៊ុយបេសកកម្មជាដើម លើកលែងតែប្រាក់វិភាជន៍គ្រួសារ។

ចំនួនប្រាក់ឈ្នួលមូលដ្ឋានត្រូវកំណត់តាមលក្ខខ័ណ្ឌដូចខាងក្រោម÷

១.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅក្នុងមួយខែម្តង ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់ខែកន្លងទៅ គឺខែមុនខែដែលមានគ្រោះថ្នាក់ ។

២.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅរៀងរាល់អឌ្ឍមាស ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់ពីរអឌ្ឍមាសបន្តបន្ទាប់មុនអឌ្ឍមាសដែលមានគ្រោះថ្នាក់ ។

៣.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅរៀងរាល់សប្តាហ៍ ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួល សំរាប់បួនសប្តាហ៍បន្តបន្ទាប់មកទល់នឹងសប្តាហ៍ដែលមានគ្រោះថ្នាក់ ។

៤.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅជាប្រចាំថ្ងៃ ឬមិនទៀងទាត់ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលប្រចាំថ្ងៃធ្វើការនិងថ្ងៃសំរាកដោយមានប្រាក់ឈ្នួលក្នុងរយៈពេលមួយខែគិតមកទល់នឹងថ្ងៃ ដែលអាក់ខានធ្វើការ ។

៥.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅក្នុងរយៈពេលលើសពីមួយខែ ប៉ុន្តែអាចបើកម្តងក្នុងមួយត្រីមាស ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលសំរាប់រយៈពេលបីខែគិតមកទល់នឹងថ្ងៃអាក់ខានធ្វើការ។

៦.បើអ្នករងគ្រោះធ្វើការក្នុងមុខរបរប្រចាំរដូវ ឬប្រកបមុខរបរមិនជាប់លាប់ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលសំរាប់រយៈពេលដប់ពីរខែគិតមកទល់ថ្ងៃ ដែលអាក់ខានធ្វើការ ។

ប្រាក់ឈ្នួលមូលដ្ឋានត្រូវគិតដូចគ្នាតាមលក្ខខណ្ឌខាងលើ បើសិនជាក្នុងរយៈពេលសាមសិបថ្ងៃគិតមកទល់ថ្ងៃគ្រោះថ្នាក់ អ្នករងគ្រោះមានផ្អាកការងារដោយមូលហេតុ ឈឺ គ្រោះថ្នាក់ធម្មតា ការសំរាលកូន ការឈប់សំរាកមានប្រាក់ឈ្នួល អវត្តមានដោយមានការអនុញ្ញាតត្រឹមត្រូវ ឬជំងឺ ឬមុខរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ការងារលាប់ឡើងវិញ ។

ក្រោយពីមានការបញ្ជាក់ពីនាយកដ្ឋានពេទ្យការងារថា បានជាសះស្បើយអាចចូលបំរើការងារបានហើយ ÷

- បើសាមីជនមិនព្រមចូលបង្ហាញខ្លួនមកធ្វើការ ក្នុងរយៈពេល៦ថ្ងៃ (គិតតែថ្ងៃធ្វើការ) គិតពីថ្ងៃទទួលលិខិតបញ្ជាក់ខាងលើ ត្រូវចាត់ទុកថាបានបោះបង់ចោលការងារ។
- និយោជកត្រូវយកចិត្តទុកដាក់ទទួលសាមីជនឱ្យចូលធ្វើការវិញ ក្នុងករណីមិនអាចទទួលបានទេត្រូវផ្តល់ប្រាក់បំណាច់ជូនសាមីជនស្មើនឹងប្រាក់មធ្យមប្រចាំថ្ងៃចំនួន ១២ ខែ។

ប្រការ ៩.-

ចំពោះករណីគ្រោះថ្នាក់ការងារ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពីម្ភៃភាគរយឡើងទៅ ឬ គ្រោះថ្នាក់ដល់ស្លាប់ និងដោយមានសេចក្តីបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាផងនោះ អ្នករងគ្រោះ ឬ សិទ្ធិវន្តមានសិទ្ធិពេញលេញក្នុងការទទួលបាននូវតាវកាលិកជាធនលាភ ។

ធនលាភ គឺជាអនុគមន៍នៃប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ និងអត្រាបាត់បង់សមត្ថភាពការងាររបស់អ្នករងគ្រោះ។ ធនលាភសំរាប់គ្រោះថ្នាក់ការងារត្រូវផ្តល់ឱ្យបន្ទាប់ពីមុខរបួសបានជាសះស្បើយ។ នៅក្នុងរយៈពេលកំពុងព្យាបាលមុខរបួស ជនរងគ្រោះមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃដូចមានចែងក្នុងប្រការ ៨ ខាងលើ។

ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំរបស់អ្នករងគ្រោះត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោម÷

- ក្នុងលក្ខខណ្ឌធម្មតា ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំស្មើនឹងចំនួនប្រាក់ឈ្នួលមូលដ្ឋានរបស់អ្នករងគ្រោះ ដូចមានកំណត់ក្នុងប្រការ ៨ ខាងលើ ក្នុងរយៈពេលដប់ពីរខែគិតមកទល់ថ្ងៃដែលអាក់ខានធ្វើការ ។
- ចំពោះអ្នករងគ្រោះដែលបំរើការក្នុងវិជ្ជាជីវៈណាមួយ ប៉ុន្តែមិនទាន់គ្រប់ដប់ពីរខែពេញលេញបើគិតមកទល់ ថ្ងៃអាក់ខានធ្វើការដោយសារគ្រោះថ្នាក់ការងារ ប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងប្រាក់ឈ្នួលជាក់ស្តែង ក្នុងរយៈពេលដែលបានធ្វើការមកទល់ថ្ងៃអាក់ខានធ្វើការនោះ ។ ទោះបីមាន ខ បញ្ញាក់យ៉ាងនេះក៏ដោយ ក៏អ្នករងគ្រោះអាចមានសិទ្ធិទទួលអត្ថប្រយោជន៍ដូចក្នុងកថាខ័ណ្ឌខាងលើ ឬប្រសើរជាង នេះ ។
- បើក្នុងចិរវេលាដប់ពីរខែគិតមកទល់ថ្ងៃមានគ្រោះថ្នាក់ការងារ អ្នករងគ្រោះបានអាក់ខានធ្វើការដោយសារ មានជំងឺ គ្រោះថ្នាក់ធម្មតា ការសំរាលកូន ការឈប់សំរាកដោយមានប្រាក់ឈ្នួល ឬអវត្តមានដោយមានច្បាប់ ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ ត្រូវស្មើនឹងប្រាក់ឈ្នួលមធ្យមក្នុងរយៈពេលដប់ពីរខែគិតមកទល់ថ្ងៃដែលអាក់ខានធ្វើការដោយគ្រោះថ្នាក់ការងារ ។

ក្នុងករណីដែលមានការបាត់បង់សមត្ថភាពការងាររហូតដល់អត្រា ៥០%អ្នករងគ្រោះមានសិទ្ធិ

ទទួលបានធនលាភ ដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម÷

$R_1 = \frac{1}{2} SX_1$ *ដែលក្នុងនោះ*

R_1 - *ជាធនលាភប្រចាំឆ្នាំ*

S - *ជាប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ*

X_1 - *ជាអត្រាបាត់បង់សមត្ថភាពការងារចិរន្តែយ៍ពី ២០% ដល់ ៥០%។*

បើអត្រាបាត់បង់សមត្ថភាពការងារអចិរន្តែយ៍លើសពី ៥០% អ្នករងគ្រោះមានសិទ្ធិទទួលបានធនលាភ ដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម÷

$R_2 = S\,[\frac{1}{2}50\% + 1.5(X_2 - 50\%)]$ *ដែលក្នុងនោះ*

R_2 - *ជាធនលាភប្រចាំឆ្នាំ*

S - *ជាប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ*

X_2 - *ជាអត្រាបាត់បង់សមត្ថភាពការងារអចិរន្តែយ៍ដែលលើសពី ៥០%។*

នៅពេលដែលគ្រោះថ្នាក់ការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិរន្តែយ៍ទាំងស្រុងនិងតំរូវឱ្យមានមនុស្សនៅចាំថែរក្សា និយោជកត្រូវតម្លើងបន្ថែម ៤០% លើធនលាភដូចមានកំណត់ខាងលើ។

នៅពេលដែលទទួលបានធនលាភ អ្នករងគ្រោះមានសិទ្ធិទទួលបានការងារដែលមានលក្ខខណ្ឌសមស្របនឹងកាយសម្បទារបស់ខ្លួន។ ក្នុងករណីនេះ និយោជកត្រូវផ្តល់ដល់ជនរងគ្រោះថ្នាក់ការងារនូវការបង្រៀនវិជ្ជាជីវៈឡើងវិញ ដើម្បីឱ្យជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារថ្មីរបស់ខ្លួន។

ក្នុងករណីដែល ភាគីទាំងពីរព្រមព្រៀងគ្នា និយោជកអាចផ្តល់ប្រាក់ធនលាភផ្តាច់តែម្តង។

ប្រការ ១០.-

និយោជកត្រូវចាត់ចែងបញ្ជូនជនរងគ្រោះមកទទួលការពិនិត្យកាយសម្បទាសាឡើងវិញ នៅនាយកដ្ឋានពេទ្យការងារបន្ទាប់ពីមុខរបួសបានជាសះស្បើយ។ កាតព្វកិច្ចនេះ អនុវត្តតែចំពោះអ្នករងគ្រោះណាដែលអាក់ខានធ្វើការងារចាប់ពីប្រាំថ្ងៃឡើងទៅ។

សោហ៊ុយចំណាយ សំរាប់ការពិនិត្យកាយសម្បទាសាឡើងវិញ ត្រូវស្ថិតនៅក្នុងបន្ទុករបស់និយោជក។

ប្រការ ១១.-

និយោជកត្រូវទទួលបន្ទុកដោយពេញច្បាប់ក្នុងការផ្តល់សោហ៊ុយសំរាប់បូជាសព និងធនលាភសំរាប់អ្នកនៅក្នុងបន្ទុកនៃអ្នករងគ្រោះថ្នាក់ការងារដល់ស្លាប់ ។ ត្រូវចាត់ទុកជាអ្នកនៅក្នុងបន្ទុកនៃអ្នករងគ្រោះ គឺជនដែលមាន លក្ខណៈសម្បត្តិដូចខាងក្រោម÷

-ភរិយា ឬប្តីពេញច្បាប់ដោយមានលិខិតបញ្ជាក់អត្រានុកូលដ្ឋាន និងមិនមានការលែងលះគ្នារហូតមកទល់ថ្ងៃមានគ្រោះថ្នាក់ ។

-កូនដែលនៅក្នុងបន្ទុករបស់ជនរងគ្រោះ ។ កូនដែលនៅក្នុងបន្ទុកជនរងគ្រោះគឺកូនដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងកូនដែលមានអាយុយ៉ាងច្រើន ១៦ឆ្នាំ ។ ប៉ុន្តែការកំរិតនេះអាចបន្ថែមដល់អាយុ ១៨ ឆ្នាំ ចំពោះកូនដែលកំពុងដាក់ឱ្យរៀនធ្វើការ និង ២២ ឆ្នាំ ចំពោះកូនដែលកំពុងបន្តការសិក្សានៅ ក្នុងគ្រឹះស្ថានសាធារណៈមធ្យមសិក្សា ឬឧត្តមសិក្សា ឬក្នុងគ្រឹះស្ថានឯកជនមធ្យមសិក្សា ឬឧត្តមសិក្សា ហើយមិនបានទទួលអាហារូបករណ៍ដោយមានការអនុញ្ញាតត្រឹមត្រូវ ព្រមទាំងកូនជាជនពិការឬមានជំងឺរ៉ាំរ៉ៃ មិនអាចព្យាបាលឱ្យជាសះស្បើយបាន ។

ប្រាក់ឧបត្ថម្ភ ដែលជាសោហ៊ុយសំរាប់ចាត់ចែងបូជាសពត្រូវកំណត់យ៉ាងតិចស្មើនឹង៩០ដងនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ឬត្រូវស្មើនឹងប្រាក់ឈ្នួលសំរាប់បីខែរបស់អ្នករងគ្រោះ ។

ធនលាភសំរាប់ផ្តល់ឱ្យអ្នកនៅក្នុងបន្ទុកត្រូវកំណត់តាមអត្រាភាគរយនៃប្រាក់ឈ្នួលជាមូលដ្ឋានប្រចាំឆ្នាំនៃអ្នករងគ្រោះហើយអត្រានេះកំណត់ដូចតទៅ÷

-សាមសិបភាគរយ "៣០%" ចំពោះប្តី ឬប្រពន្ធអ្នករងគ្រោះ

-ដប់ប្រាំភាគរយ "១៥% " ចំពោះកូនទី១ និងទី២ ដែលកំព្រាឪពុក ឬម្តាយ

-ដប់ភាគរយ "១០% " ចំពោះកូនទី៣ តទៅដែលកំព្រាឪពុក ឬម្តាយ

ប៉ុន្តែចំនួនសរុបនៃធនលាភសំរាប់អ្នកនៅក្នុងបន្ទុកមិនអាចលើស ៨៥% នៃចំនួនប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំនោះឡើយ ។

សិទ្ធិនៃការទទួលធនលាភនៃប្តី ឬប្រពន្ធដូចមានកំណត់តាមលក្ខខណ្ឌខាងលើត្រូវផុតរលត់ក្នុងករណីជនទាំងនោះរៀបអាពាហ៍ពិពាហ៍ម្តងទៀត ។

ប្រាក់ធនលាភនេះ អាចបើកប្រចាំខែ ឬអាចបើកផ្តាច់តាមការព្រមព្រៀងគ្នារវាង និយោជក និងសិទ្ធិវន្តនៃអ្នករងគ្រោះ។

ប្រការ ១២.-

ដោយអនុលោមតាមប្រភេទនៃមុខរបួស និងលក្ខណៈទូទៅផ្សេងទៀតដូចជា អាយុ កំលាំងកាយ ស្មារតី សម្បទា និងលក្ខណៈសម្បត្តិនៃវិជ្ជាជីវៈ អត្រានៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវកំណត់ក្នុង ឧបសម្ព័ន្ធទី ៥នៃប្រកាសនេះ ។

ប្រការ ១៣.-

នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងលើកសំណើប្រភេទជំងឺវិជ្ជាជីវៈ។

ប្រការ ១៤.-

ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវទទួលពិន័យឬទទួលទោសដូចមានចែងក្នុងជំពូក ទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ ១៥.-

ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៥៨ សកអ ចុះថ្ងៃទី ១២ ខែកុម្ភៈឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៦.-

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទាខេត្ត ក្រុង " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-សមាគមនិយោជក " ដើម្បីជ្រាប "
-សហព័ន្ធសហជីព " ដើម្បីជ្រាប "
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធទី១នៃប្រកាស
លេខ សកបយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

លោក/លោកស្រី...

ម្ចាស់ ឬនាយកសហគ្រាស ឬក្រុមហ៊ុន ....

អាស័យដ្ឋាន..

....

គោរពជូន

លោកប្រធាន

- ☐ នាយកដ្ឋានសន្តិសុខសង្គម [១]
- ☐ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ឬក្រុង...

<u>កម្មវត្ថុ</u> ៖ ប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

១_កាលបរិច្ឆេទនៃគ្រោះថ្នាក់ការងារ ៖

ម៉ោង.............ថ្ងៃទី............ខែ..............ឆ្នាំ.......ទីកន្លែង.................

២_ប្រភេទគ្រោះថ្នាក់ការងារ...

....

....

៣_ចំនួនអ្នករងគ្រោះ ៖

- ស្លាប់:..
- របួសធ្ងន់:..
- របួសស្រាល:..

៤_មូលហេតុនៃគ្រោះថ្នាក់ "បរិយាយលំអិត "...

....

....

[១] គូសក្នុងចតុកោណដែលត្រូវផ្ញើ

ធ្វើនៅ...............ថ្ងៃទី.....................

ហត្ថលេខានិយោជក ឬម្ចាស់សហគ្រាស

ឧបសម្ព័ន្ធទី ២ នៃប្រកាស

លេខ សកបយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

កំណត់ហេតុ

អង្កេតគ្រោះថ្នាក់ការងារ

ឆ្នាំ .... ខែ .... ថ្ងៃទី .... ម៉ោង .... គណៈកម្មការអង្កេតគ្រោះថ្នាក់ការងាររបស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចុះធ្វើអង្កេតករណីគ្រោះថ្នាក់ ដែលបានកើតឡើងនៅ ៖

សហគ្រាស/ក្រុមហ៊ុន:..

អាស័យដ្ឋាន:..

១- កំរិតគ្រោះថ្នាក់

☐ ស្លាប់

☐ របួសធ្ងន់

☐ របួសស្រាល

២- ប្រភេទគ្រោះថ្នាក់ : (ភ្លើងឆក់, ម៉ាស៊ីនគាប, ធ្លាក់ពីទីខ្ពស់, សំភារៈ ឬឧបករណ៍ធ្លាក់ ឬសង្កត់លើ, ផ្ទុះឧបករណ៍សម្ពាធខ្ពស់ ។ល។)

☐ ....

☐ ....

☐ ....

☐ ....

៣- សមាសភាពគណៈកម្មការអង្កេត

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

៤- ជីវប្រវត្តិជនរងគ្រោះ

☐ ឈ្មោះ...ភេទ..អាយុ...

- មុខជំនាញ..
- អតីតភាពមុខជំនាញ..
- អតីតភាពការងារ...
- រូបភាពផ្តល់បៀវត្ស..
- សញ្ជាតិ..
- ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ
  - ☐ ធ្លាប់
  - ☐ មិនធ្លាប់

☐ ស្ថានភាពគ្រួសារ (អ្នកនៅក្នុងបន្ទុក, កិរិតជីវភាព) ....

☐ ឈ្មោះ...ភេទ..អាយុ...

- មុខជំនាញ..
- អតីតភាពមុខជំនាញ..
- អតីតភាពការងារ...
- រូបភាពផ្តល់បៀវត្ស..
- សញ្ជាតិ..
- ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ
  - ☐ ធ្លាប់
  - ☐ មិនធ្លាប់
- ស្ថានភាពគ្រួសារ (អ្នកនៅក្នុងបន្ទុក, កិរិតជីវភាព) ....

៥-ទិដ្ឋភាពនៃគ្រោះថ្នាក់ (អនុលោមតាមរបាយការណ៍របស់គ្រូពេទ្យប្រចាំសហគ្រាស និង/ឬ មន្ត្រីអង្កេត)

☐ ថ្ងៃ.............................ខែ.....................ឆ្នាំ..................ម៉ោង...

☐ មុន ឬក្រោយពេលធ្វើការ

☐ ពេលម៉ោងបន្ថែម

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

៦-សាក្សី

☐ ....

☐ ....

☐ ....

☐ ....

៧-មតិនិយោជក.

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

៨-មតិប្រតិភូបុគ្គលិក ឬ សហជីព

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

៩-មូលហេតុនៃគ្រោះថ្នាក់

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

១០-វិធានការទប់ស្កាត់

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

១១-សេចក្តីសន្និដ្ឋានរបស់គណកម្មការអង្កេត

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

នាយកសហគ្រាស ឬតំណាង　　　　សាក្សី　　　　ប្រធានគណៈកម្មការអង្កេត

ឧបសម្ព័ន្ធទី៣

ប្រកាសលេខ:................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គភាព/ក្រុមហ៊ុន :............................

អាសយដ្ឋាន :......................................

បញ្ជីគ្រោះថ្នាក់ការងារ

ល.រ/No.		ឈ្មោះ NAME	មុខរបរ JOB	ភេទ SEX	អាយុ AGE			អតីតភាពការងារ employment age	អតីតភាពមុខជំនាញ SKILLED SENIORITY			កំរិតគ្រោះថ្នាក់ ACCIDENT SEVERITY			ចំនួនថ្ងៃឈប់ធ្វើការ WORKING DAY LOSS	សោធនណិវត្ត BENEFITS (X 1000 Riels)	ប្រភេទគ្រោះថ្នាក់ TYPE OF THE ACCIDENT	មូលហេតុ CAUSES				វគ្គបំប៉នការពារសុវត្ថិភាព SAFETY TRAINING (yes/ no)
គ្រោះថ្នាក់ ការងារ LABOUR ACCIDENT	ជនរងគ្រោះ VICTIM				តិចជាង ៣០ < 30 YEARS OLD	ពី៣០ ទៅ ៤០ FROM 30-40 YEARS OLD	៤០ឡើង > 40 YEARS OLD		តិចជាង ៥ឆ្នាំ <5 years	ពី៥ដល់ ១០ឆ្នាំ FROM 5 - 10 YEARS	១០ឆ្នាំឡើង >10 YEARS	ស្លាប់ DEATH	ពិការតិច២០%ឡើង < 20% OF PERT. INCAPACITY	តិចជាង ២០% > 20% OF PERT. INCAPACITY				ឧបករណ៍ផលិតកម្ម PRODUCTIVE AGENCIES	អនាម័យការងារ LABOUR HYGIENE	សំភារៈការពារខ្លួន PER. PROT. EQUIPMENT	រំលោភបទបញ្ជា RULE VIOLATION	
១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣

១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣
សរុប																						

ធ្វើនៅ............ថ្ងៃទី ខែ ឆ្នាំ

ប្រធានអង្គភាព

អង្គភាព/ក្រុមហ៊ុន :................................

អាសយដ្ឋាន :................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៤

នៃប្រកាសលេខ:................

របាយការណ៍សរុបគ្រោះថ្នាក់ការងារ

ប្រភេទគ្រោះថ្នាក់ Type of Accident	ចំនួនគ្រោះថ្នាក់ការងារ (ដង) Number of accident (time)			ចំនួនមនុស្សគ្រោះថ្នាក់ការងារ (នាក់) Number people accident (person)													ចំនួនថ្ងៃឈប់ធ្វើការ Working day loss	ទានការងារ Benefits (x 1000 Riels)	មូលហេតុ Causes					ហាត់ហ្វឹកហាត់សុវត្ថិភាព Saf. Training (yes/ no)
						ស្លាប់ Death		>20%		<20%	អាយុ Age			អតីតភាពមុខជំនាញ Skilled Seniority								ល្មើសបទបញ្ជា RULE VIOLATION		
	សរុប Total	ស្លាប់ Death	ច្រើននាក់Many People	សរុប Total	ស្រី Female	សរុប Total	ស្រី Female	សរុប Total	ស្រី Female		តិចជាង ៣០ < 30 years old	ពី៣០ ទៅ ៤០ From 30 to 40 years old	៤០ឡើង > 40 years old	តិចជាង ៥ឆ្នាំ < 5 years	ពី៥ដល់ ១០ឆ្នាំ From 5 - 10 years	១០ឆ្នាំឡើង >10 years			ឧបករណ៍ផលិតកម្ម Productive Agencies	អនាម័យការងារ Labor hygiene	សំភារៈការពារបុគ្គល Per. Prot. Equipment	អ្នកគ្រប់គ្រង Manager	កម្មករនិយោជិត Workers	
១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣	២៤	២៥

១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣	២៤	២៥
សរុប																								

ធ្វើនៅ............ថ្ងៃទី ខែ ឆ្នាំ

ប្រធានអង្គភាព

ឧបសម្ព័ន្ធទី ៥ នៃប្រកាស

លេខ: សកបយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លក្ខណៈវិនិច្ឆ័យសំរាប់ការចាត់ថ្នាក់នៃ
ការបាត់បង់សមត្ថភាពការងារ

ការបាត់បង់សមត្ថភាពបំពេញការងារត្រូវចាត់ថ្នាក់ជា ៤ ប្រភេទ :

ប្រភេទទី ១ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់សាមីជនដែលមានការទ្រុឌទ្រោមទាំងស្រុងនៃមុខងារសំខាន់ៗ និងជាសារវន្តចំនួនមួយ ឬច្រើនរបស់សរីរាង្គកាយ ។ ជនពិការពុំអាចធ្វើការងារបំរើខ្លួនឯងបាន និងតម្រូវឱ្យមានអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។

ប្រភេទទី ២ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលមានការទ្រុឌទ្រោមធ្ងន់ ឬស្រាល នៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ ។ ជនពិការអាចប្រកបការងារបាននៅក្នុងករណីពិសេស ។ សាមីជននេះអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់ខ្លួនមួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃដោយមិនបាច់ពឹងផ្អែកជំនួយជាអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ ។

ប្រភេទទី ៣ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលមានការចុះថយនៃសមត្ថភាពធ្វើការងារ ។ ជនពិការអាចបំពេញការងារបាននៅក្នុងករណីដែលបានកំណត់ ហើយមិនទាមទារឱ្យមានអ្នកដទៃជួយក្នុងជីវភាពប្រចាំថ្ងៃឡើយ ។

ប្រភេទទី ៤ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលសមត្ថភាពការងារត្រូវថយចុះ និងសភាពរបស់ខ្លួនតម្រូវឱ្យផ្លាស់ប្តូរវិជ្ជាជីវៈ ឬតម្រូវឱ្យផ្លាស់ប្តូរលក្ខណៈការងារ ។

ប្រភេទទី ១

សំណល់នៃអាហ្វិចស្យុង "ជំងឺត្រូម៉ា" "ការប៉ះទង្គិច" បណ្តាលពីគ្រោះថ្នាក់នៃការងារ		អត្រាបាត់បង់សមត្ថភាពការងារ(%)
ក-ក្បាល មុខ ក :		
១-ការប៉ះទង្គិចលលាដ៍:		
-ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិនៃពាក្យសំដី	៖	៧០-៨០
-ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិសាច់ដុំ	៖	៧០-៨០
-ឆ្កួតជ្រូកញឹកញាប់ កើតមានច្រើនដងក្នុងមួយសប្តាហ៍	៖	៧៥-១០០
-វិលមុខ ភ្លេចភ្លាំង "ឆ្កួតជ្រូកស្រាល" កើតឡើងដោយធ្ងន់ធ្ងរ	៖	៤០-៨០
-មានសិក "ប្រាជ្ញាស្មារតី" "ខូចខាត" ភាពវិកលចរិត ភាពលីលា" ធ្ងន់ធ្ងរ	៖	៦១-១០០
២-អន្ធការភ្នែកទាំងពីរ,កំរិតគំហើញ សរុប ១/២០	៖	៨០
៣-អន្ធការទាំងស្រុងនៃភ្នែកទាំងពីរ "ខ្វាក់"	៖	៩០
៤-បាត់បង់ឆ្អឹងថ្គាមខាងក្រោម	៖	៦០-៧០
៥-ជំងឺបំពង់សំលេង ដើមក ហត់ដង្ហើមមិនធូរស្រាល	៖	៥០-៦០

ខ.ខ្លួន និងសរីរាង្គក្នុងខ្លួន

១-វះកាត់សួត សមត្ថភាពដកដង្ហើមថយចុះជាង៥០ភាគរយ

សុខភាពទូទៅ ត្រូវវង្វេងគ្រោះ "ថយចុះ" : ៥៥-៧៥

២-ប៉ះពាល់ដល់ស្រោមបេះដូង បណ្តាលមកពីកាំកាស បើរីករាល "សាច់បេះដូង" ឬការដី "

ប្រើសបេះដូងបង្កឱ្យមានវិបត្តិសង្វាក់បេះដូង : ៥៥-៧០

គ.ឆ្អឹងខ្នង : ជំងឺឆ្អឹងខ្នងជាមួយនឹងការកៀបសៀតខួរឆ្អឹងខ្នង :

១-ខ្វិនសងខាងមិនពេញលេញនៃអវៈយវៈក្រោម លំបាកលំបិនទូវដំណើរ

និងវិបត្តិសាច់ដុំរលីង និងស : ៤០-៧០

២-ខ្វិនសងខាងទាំងស្រុងនៃអវៈយវៈក្រោម : ៧០-៨០

៣-ខ្វិនទាំងបួន "ដៃពីរ ជើងពីរ" មិនពេញលេញ : ៨០-៩០

៤-ខ្វិនបួនទាំងស្រុង "អាច់ទាំងជើង ទាំងដៃ" : ១០០

៥-អាការៈរោគនៃកន្ទុយសេះ "កីស្ទីរ៉ាំស" ខ្វិនសងខាង វិកលភាព សាច់ដុំរលីង និងស

បាត់បង់អស់រង្វិចអាគិល : ១០០

ឃ.ពោះ និងសរីរាង្គក្នុងពោះ :

-ជំងឺពោះវៀនធំ ទ្វារលាមកសិប្បនិម្មិត : ៤០-៧០

ង.អវៈយវៈ :

១-កាត់ដៃទាំងពីរ "មិនចំពោះកាត់ត្រឹមណា" : ៧៥-៨៥

២-កាត់ប្រអប់ជើងទាំងពីរ : ៧០-៨០

៣-កាត់ជើងទាំងពីរ "មិនចំពោះកាត់ត្រឹមណា" : ៧០-៨០

៤-កាត់ដើមដៃម្ខាង និងប្រអប់ជើងម្ខាង

-មានជើងដាក់ជំនួសបាន "ជើងសិប្បនិម្មិត" : ៧៥-៨០

-គ្មានជើងដាក់ជំនួសបាន : ៨០-៩០

៥-បាត់បង់អវៈយវៈបី "ដៃពីរជើងមួយ ឬ ផ្ទុយ" : ១០០

៦-ខ្វិនទាំងស្រុងនៃអវៈយវៈពីរ ឬច្រើនជាងនេះ "ឬមួយអវៈយវៈលើ ២ ឬមួយអវៈយវៈ

ក្រោម២ ឬមួយអវៈយវៈលើមួយក្រោមមួយ : ៧០-៩៥

ប្រភេទទី ២

ក.ក្បាល ខួរ ក :

១-ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ លំបាកលំបិននៅដំណើរ : ៤០-៧០

២-ថ្លង់ និងភាពគ : ៤០-៦០

៣-ឆ្កួតជ្រូកច្រំដែល : ៣០-៤៥

៤-វិលមុខឆ្កួតជ្រូកស្រាល "បីដងក្នុងមួយសប្តាហ៍" : ៣០-៤០

៥-ឆ្កួតជ្រូកដោយអន្លើ កើតវិបត្តិជាប់ៗគ្នា : ៣០-៥០

៦-អាហ្វាស៊ី - និយាយមិនឮ : ២០-៥០

៧-វិបត្តិណឺរ៉ូ បន្ទាប់ពីការប៉ះទង្គិច ឬអាការៈរោយបន្ទាប់ពីការប៉ះទង្គិច : ៣០-៤០

៨-ភាពល្ងិតល្ងៃ "អាល់ស្មេនី" បន្ទាប់ពីការប៉ះទង្គិច " : ៣០-៤០

៩-ហ៊ីពែរតេម៉ូស្យុង "ឆាប់រំភើបចិត្តខ្លាំងពេក"	៖	៣០-៤០
១០-ផ្លោកនោមស្វ័យប្រវត្តិ "អាការៈរោគកីស្ទីវ៉ាល់"	៖	២០-៤០
១១-មានសិក (សតិបញ្ញា) ទន់ខ្សោយ	៖	៤៥-៦០
១២-មានសិកស្រុតចុះ	៖	៤០
១៣-ថ្លង់សងខាងទាំងស្រុង	៖	៤៥
១៤-ដំបៅបំពង់សំឡេង-វះចោះបំពង់ខ្យល់	៖	៥០-៦០
១៥-បំពង់អាហាររួមតូច តម្រូវឱ្យអវៈយវៈក្រពះ	៖	៤០-៦០
១៦-គំហើញនៃភ្នែកទាំងពីរថយចុះ		
-កម្រិតគំហើញ (អាគ្វីតេ) ២/១០	៖	៦០
-កម្រិតគំហើញ (អាគ្វីតេ) ១/១០	៖	៧០
១៧-បាត់បង់ឆ្អឹងថ្គាមខាងលើ	៖	៥០-៦០
១៨-ភ្ជាប់ឆ្អឹងថ្គាមមានសមត្ថភាពលេបតែសារធាតុរាវ	៖	៤០-៦០
១៩-ខ្វិនសាច់ដុំអណ្តាតទាំងស្រុង "ងាប់អណ្តាត"	៖	៥០
២០-អណ្តាតដាច់ដោយសារមិនទង្គិច	៖	៥០

ខ-ទ្រូង និងសរីរាង្គក្នុងទ្រូង :

១-វះកាត់សួត "ពូម៉ុងអឺចតូមី" សមត្ថភាពដកដង្ហើមថយចុះតិចជាង៥០%	៖	៣៥-៤៥
២-កើតជំងឺនៅស្រោមបេះដូង "បញ្ចូន័យកោស បេរីការដ មីញ៉ូការដ សាច់បេះដូង" ប្រើស "វ៉ាល់វ៉ី" មិនបណ្តាលឱ្យមានវិបត្តិដល់មុខងារសំខាន់ៗរបស់បេះដូង	៖	៣០-៥០

គ-ឆ្អឹងខ្នង :

១-ខ្វិនសងខាងមិនពេញលេញ មានសមត្ថភាពអាចរំកិលខ្លួនបាន	៖	២៥-៤០
២-ខ្វិនចំហៀងខ្លួនសងខាង	៖	២៤-៤០
៣ បាក់ឆ្អឹងតួច ឬបញ្ហាវិបត្តិនៃហោច់ជុំលើង និង៧	៖	២៥-៣៥

ឃ-ពោះ និងសរីរាង្គក្នុងពោះ :

១-ការប៉ះទង្គិចផ្ទៃពោះ ប៉ះពាល់ដល់ក្រពះជាមួយនឹងផលវិបាក : ដំបៅស្លួយ ខូះឈាម ស្លេកស្លាំង (anémie) ស្លេកស្លាំង	៖	៣៥-៤៥
២-វះកាត់ក្រពះ	៖	៤០ -៦០
៣-វះកាត់ពោះវៀនតូចលើសពីមួយម៉ែត្រ ជាមួយនឹងវិបត្តិនៃការរំលាយអាហារ	៖	៣៥-៦០
៤-ដំបៅពោះវៀនតូច និងធ្លាយរន្ធធំនៅភាគខាងលើ	៖	២៥-៤០
៥-រន្ធធ្លាយធំនៃពោះវៀនធំជាមួយនឹងការហូរលាមក	៖	៣០-៤០
៦-រលោះផ្លោកនោមនៅផ្ទៃពោះ "រន្ធនោមសិប្បនិម្មិត	៖	៣០-៤០
៧-កាត់តម្រងនោមម្ខាងចោល : អ៊ុយរេឈាម ០.៦ - ១ក្រាមក្នុងមួយលីត្រ	៖	៣៥-៤៥
អ៊ុយរេឈាមច្រើនជាងមួយក្រាមក្នុងមួយលីត្រ	៖	៤៥-៦៥

ង-ត្រគាក សរីរាង្គនៃត្រគាក ប្រដាប់បន្តពូជ "អង្គជាតិ" :

១-បាក់ឆ្អឹងត្រគាកជាមួយនឹងការខូចទ្រង់ទ្រាយត្រគាករបស់ស្ត្រីក្នុងអាយុកាលអាចឱ្យកំណើតកូនបាន	៖	៣០-៤០
២-វះកាត់ស្បូននៃស្ត្រីមិនដែលមានកូន	៖	៣៥-៤៥

៣-កាត់សុដន់ចោលទាំងពីរពីរយក្មេង ៖ ៣៥-៤៥
៤-កាត់លិង្គបុរសនៅមិនទាន់មានកូន ៖ ៣៥-៤៥
៥-បាត់បង់ពងស្វាសទាំងពីរនៅបុរសមិនដែលមានកូន ៖ ២៥-៤០

ខ-អវយវៈ :

១-បាត់បង់ប្រអប់ដៃម្ខាង ៖ ៣៥-៤០
២-កាត់ត្រង់សន្លាក់ឆ្អឹងកដៃ ៖ ៣៥-៤០
៣-កាត់កំភួនដៃ ៖ ៤០-៤៥
៤-កាត់ត្រង់សន្លាក់ឆ្អឹងកែងដៃ ៖ ៤០-៤៥
៥-កាត់ឆ្អឹងដើមដៃ :
-ពាក់កណ្ដាលខាងក្រោម ៖ ៤៥-៥០
-ពាក់កណ្ដាលខាងលើ ៖ ៥០-៥៥
៦-កាត់ត្រង់សន្លាក់ឆ្អឹងស្មា ៖ ៥៥-៦០
៧-ខ្វិនទាំងស្រុង "ងាប់" នៃដៃម្ខាង ៖ ៤៥-៥០
៨-អាការៈរោគនៃការឈើចាប់កូសាល់ "កូសាល់ឈី" ខូចខាតទាំងស្រុងនៃដើមដៃម្ខាង ៖ ៤៥-៥០
៩-កាត់ស្មងម្ខាង ៖ ៣៥-៥០
១០-កាត់ត្រង់សន្លាក់ជង្គង់ ៖ ៣៥-៤០
១១-កាត់ភ្លៅ ៖ ៣៥-៤០
១២-ខ្វិនទាំងស្រុង "ងាប់" នៃជើងម្ខាង ៖ ៤៥
១៣-ភ្ជាប់ឆ្អឹងចង្កេះជាមួយនឹងរញ្ជួសាច់ភ្លៅ ៖ ៤៥
១៤-កាត់សន្លាក់ឆ្អឹងចង្កេះ "គ្មានសន្លាក់ឆ្អឹងចង្កេះ" ៖ ៥០-៧០

ប្រភេទទី ៣

ក-ក្បាល មុខ ក :

១-របាត់ស្បែកលលាដ៍ ៖ ១៥-៣០
២-កាត់ឆ្អឹងលលាដ៍ចោលមួយចំណែក :
-វិជ្ជមាត្រលើសពីរ ៦ ស.ម ៖ ២០-៣០
-វិជ្ជមាត្រលើសពី ១០ ស.ម ៖ ៣០-៤០
៣-អង្គធាតុជទៃនៅក្នុងប្រអប់លលាដ៍ ៖ ២០-៣០
៤-ហេមីប៉ារេស៊ី ៖ ២០-៤០
៥-និយាយមិនឮស្ទើរតែទាំងស្រុង ៖ ២០-៣០
៦-ឆ្កួតជ្រូកទូទៅ :
-រម្ងើល "ម្ដងទៅពីរដងក្នុងមួយខែ" ៖ ១៥-៣៥
-កម្រ " ៣ដងទៅ ៤ដងក្នុងមួយឆ្នាំ " ៖ ១០-១៥
៧-វិលមុខ ភ្លេចភ្លាំង "ឆ្កួតជ្រូកស្រាល" "សណ្ដានស្រាល" ៖ ២០-៣០
៨-ឆ្កួតជ្រូកតិចតួច "មិនជាឆ្កួតជ្រូក" យ៉ាកសូន " ម្ដងក្នុងមួយសប្ដាហ៍ ៖ ២០-៣០
៩-ចលនាមិនធម្មតា "ញ័រទទ្រើកប្រកាច់... លំបាកលំបិនក្នុងការងារនៃភាពញញល្បៀង

"ផាក់លោត"	៖	១០-៤០
១០-អាការៈរោគផ្តាច់ខ្លួន "ស៊ូបហ្វ្រិកទីហ្វ" ជាប់បន្ទាប់ពីការរបួសខួរក្បាលស្បូងខួរ"	៖	២០-៣០
១១-អាស្តេនីបន្ទាប់ពីការប៉ះទង្គិច "សណ្ឋានមធ្យម .កណ្តាល"	៖	២០-៣០
១២-ហ៊ីស្តេរីអេម៉ូទីវិត "ភាពតាប់រំភើបចិត្តខ្លាំងពេក" បារម្ភ. មនោមតិត "សណ្ឋានមធ្យម"	៖	២០-៣០
១៣-សភាពស្រុតចុះនៃឈើរ៉ូ "មធ្យម ស្លម"	៖	១០-៣០
១៤-សណ្ឋានឆ្កួតជ្រូកនាពេលព្រលប់ "សន្និប្រកាស"	៖	២៥-៣០
១៥-ថ្លង់ទាំងសងខាងមិនពេញលេញ	៖	៣០-៤០
១៦-បំពង់ច្រមុះរួមតូច "កុងដ៏ណោសាល់" ដកដង្ហើមតាមមាត់	៖	២០-៣០
១៧-អន្ធការភ្នែកម្ខាង ខ្ទេចទ្រនំទ្រាយគ្រាប់ភ្នែកម្ខាងទៀត	៖	២៥-៣០
១៨-កាត់គ្រាប់ភ្នែកម្ខាងចោល		
-មានលទ្ធភាពដាក់កែវភ្នែកជំនួសបាន "កែវភ្នែកសិប្បនិម្មិត"	៖	២៥-៣០
-គ្មានលទ្ធភាពដាក់កែវភ្នែកជំនួសបាន	៖	៣០-៣៥
១៩-បាក់ឆ្អឹងថ្គាមខាងលើជាមួយនឹងផ្លែឆ្អឹងមានគុណវិបត្តិ និងភ្ជាប់		
ខៀតផ្គុំ ថ្គាម អសមត្ថភាពនៃការរំលាយអាហារ	៖	៣០-៤០
២០-បាក់ឆ្អឹងថ្គាមក្រោម ផ្លែឆ្អឹងមានគុណវិបត្តិ ការរើឡើក ខុស កន្លែងនៃសន្លាក់ធ្មេញ		
"កន្លែងដែលធ្មេញលើនិងក្រោមប៉ះគ្នា"	៖	២០-៣០
២១-សន្លាក់ថ្គាមជាប់រឹងអសមត្ថភាពញែកច្រានឆ្អឹងថ្គាមទាំងពីរច្រើនជាង ១០ស.ម	៖	១៥-៤០
២២-បាត់បង់អណ្តាតមួយភាគ វិបត្តិនៃពាក្យសំដី	៖	២០-៣០
២៣-ថ្លង់ ត បណ្តាលមកពីអនុភាព សន្ទុះខ្យល់ធ្លាក់នៃការផ្ទុះ		
-ភាពធ្ងន់ធ្ងរ	៖	៤០-៦០
-ធ្ងន់ធ្ងរមធ្យម	៖	២០-៤០

ខ-សួត និងសរីរាង្គក្នុងទ្រូង :

១-បាក់ឆ្អឹងជំនី ខ្ទេចទ្រុងទ្រូងខាង "ប្រអប់ទ្រូង" ជាមួយនឹងការរលាកនៃដំបៅធ្លុះធ្លាយស្រោមសួត	៖	២៥-៣៥
២-វិបត្តិនិងការលោតកើតឡើតនៃដំណៅស្រោមសួត "ឈាមក្នុងស្រោមសួត ខ្យល់ក្នុងស្រោមសួត		
ស្រោមសួតស្អិតជាប់គ្នា កត់ដង្ហក់ "ហេម៉ូថូរ៉ាក់" ធីប៉ូថូរ៉ាក់ ប្លេរីយ៉ូត"	៖	២០-៣០
៣-វះកាត់សួត "ផ្នែម៉ូណេក្តូមី" សមត្ថភាពដកដង្ហើមថយចុះតិចជាង ៥០ភាគរយ	៖	២៥-៣៥
៤-ការរួមតូចនៃបំពង់អាហារ មកពីការប៉ះទង្គិច ឬមកពីការលេបដោយគ្រោះថ្នាក់នៃរូបធាតុ		
ឱ្យរលាក "ស្ទ្រីដក្ទីប"	៖	២០-៤០

គ-ឆ្អឹងខ្នង :

១-រឹងឆ្អឹងខ្នង ចលនានៃចំណុត និងបង្វិល មានលក្ខខណ្ឌបន្ថយចុះ និងឈឺចាប់	៖	២៥-៤០
២-អាការៈរោគនៃកន្ទុយសេះ ទល់នោមមិនពេញលេញ	៖	១០-៣០

ឃ-ពោះ និងសរីរាង្គក្នុងពោះ :

១-វះកាត់ក្រពះ :		
-គ្មានវិបត្តិ	៖	២០-២៥
-មានវិប្បដិបត្តិជាប់ស្អិត វិបត្តិនៃការរំលាយអាហារ សុខភាពទូទៅថយចុះ	៖	២៥-៣៥
២-វះកាត់ពោះវៀនតូច លើសពីមួយម៉ែត្រ គ្មានវិបរិត និងគ្មានវិបត្តិដល់ការរំលាយអាហារ	៖	២៥-៣០

៣-ដំបៅធ្លាយនៃពោះវៀន :		
-រន្ធធ្លាយធំនៅភាគខាងលើ	៖	២៥-៤០
-រន្ធធ្លាយធំនៅភាគខាងក្រោម	៖	២០-៣០
៤-រន្ធធ្លាយតូចបណ្ដាលឱ្យចូលនូវឧស្ម័ន និងទឹកលាមក " លាមកវារី "	៖	២០-៣០
៥-ការប៉ះពាល់ដល់ស្ពិនក្ទ័រទ្វារលាមក ជាមួយនឹងការបន្ទោបង់ " ជុះទប់មិនឈ្នះ "	៖	២៥-៣០
៦-ជំងឺថ្លើមជាមួយនឹងវិបត្តិនៃមុខងារថ្លើម	៖	១៥-៣០
៧-វះកាត់តម្រងនោមម្ខាង ម្ខាងទៀតធម្មតា	៖	២៥

ខ.ត្រគាក សរីរាង្គនៃត្រគាក អង្គជាតិ :

១-រន្ធរំហែកធ្លាយ " អ៊ិនធិចរេត " នៃរបេរីណេ "	៖	២០-៤០
២-ការរួមតូចនៃទ្វារនោម " អ៊ុយរ៉េត្រ "		
-តម្រូវឱ្យព្យាបាលដោយពង្រីកជាទៀងរាល់ខែ	៖	១០-៣០
-ជាមួយនឹងរន្ធរំហែកធ្លាយ	៖	២៥-៤០
៣-កាត់លិង្គបុរសមានកូនរួចហើយ	៖	២៥-៣៥
៤-វះកាត់ស្បូនស្ត្រីអាយុតិចជាង៤៥ឆ្នាំ ដែលមានកូនរួចហើយ	៖	២៥-៣៥
៥-កាត់ស៊ុដេនទាំងពីរចោលនៅស្ត្រីដែលមានកូនរួចហើយ	៖	២៥-៤០
៦-រន្ធធ្លាយពីថ្លោកនោមទៅទ្វារមាស " ថ្លោកនោម ទ្វារមាស "	៖	២០-៣០

គ.អវយវៈ :

១-បាត់បង់មេដៃ និងចង្អុលដៃ	៖	២៥-៣០
២-បាត់បង់ម្រាមដៃបួន មិនចំពោះម្រាមណា	៖	២៥-៣០
៣-បាត់បង់ម្រាមដៃទាំងប្រាំ	៖	៣០-៣៥
៤-ម្រាមទាំងប្រាំរឹងក្រញង់	៖	២៥-៣០
៥-សន្លាក់ក្លែងក្លាយ ខុសកន្លែង នៃឆ្អឹងកំភួនដៃទាំងពីរ	៖	២០-៣០
៦-កែងដៃរឹងក្រញង់ ពរិយាបថសន្ទឹងពិ ១១០-១៨០អង្សា	៖	២៥-៤០
៧-បាត់ឆ្អឹងដើមដៃជាមួយនឹងសន្លាក់ក្លែងក្លាយ	៖	២៥-៣៥
៨-បាក់កណ្ដាលនៃឆ្អឹងដើមដៃ ផ្នែកឆ្អឹងមានគុណវិបត្តិជាមួយនឹងលក្ខខណ្ឌបន្ថយចុះនៃចលនារបស់ស្មា	៖	២៥-៣០
៩-ស្មារឹងក្រញង់ :		
-កន្ធែកចេញ " អាប់ឌុលស្យុង " ពី ៤៥ អង្សា	៖	២៥-៣០
-កន្ធែកចេញពី ១០ អង្សា	៖	៣០-៣៥
១០-ខ្វិនណឺរ៉ូ ម៉េដ្យង់	៖	២៥-៣០
១១-ខ្វិនណឺរ៉ូ រ៉ាដ្យាល់នៅភាគខាងលើនៃទ្រីសិបស ប្រអប់ដៃធ្លាក់ចុះវិកវក់	៖	២៥-៣០
១២-ខ្វិនឫសណឺរ៉ូខាងលើ " រ៉ាឌីគុយឡែរ " ធុនឌុចចេនន៍អេរ៉ុស " ខ្វិនសាច់ដុំ ដែលតួអឺដប៊ីសិបស ប្រាចាល់មុខ និងឡុងស៊ូឌីណាទ័រ "	៖	២៥-៣០
១៣-ខ្វិនឫសណឺរ៉ូខាងក្រោម ខ្វិនសាច់ដុំផ្ដេជីសបិរម្រាមដៃ	៖	២៥-៣៥

១៤-អាការៈរោគវ្លិចគ្លូន " រួញ ឡុងផ្ដេជីសស័រម្រាមដៃដោយហ៊ីប៉ូវ៉ាស្គុយឡារីសាស្យុន

ប្រភពនៃការប៉ះទង្គិច : ២០-៣៥

១៥-បាត់បង់ម្រាមជើងទាំងប្រាំ និងឆ្អឹងបាតជើង : ២០-២៥

១៦-បាត់បង់ប្រអប់ជើង សល់តែការលោរមូម " ឆ្អឹងកែងជើង " ឬកាត់សន្លាក់តាមរបៀប
ចូប៉ារតិ : ២៥-៣០

១៧-ការវះកាត់តាមរបៀបលីសហ្វ្រង់កិ រីការជិ ពីរូគួលហ្វិ : ២៥-៣០

១៨-កាត់សន្លាក់កជើង : ៣៥

១៩-បាក់ផាសឆ្អឹង ផ្លាតូទីប៊ីយ៉ា ជង្គង់រឹងក្រញូង់ : ២០-៣០

២០-បាក់ឆ្អឹងស្មងទាំងពីរ ផ្ទៃឆ្អឹងមានគុណវិបត្តិ ស្មងវៀចជាមួយនឹងការរួញខ្លីលើសពិ ៥ ស.ម : ២០-២៥

២១-សន្លាក់ក្លែងក្លាយនៃស្មង : ៣៥-៥០

២២-បាក់ ឬកាត់ត្រង់សន្លាក់អង្កុញ ជង្គង់រឹងក្រញូង់ បត្រ្បិត ឆ្នាខ្វៀសេបសិ : ១៥-២៥

២៣-កំរែអាល រលេស្បូងនៃការប៉ះទង្គិចប៉ះពាល់ដល់សន្លាក់ជង្គង់ ស្មងបត់បានពី ១៥០-១៣៥អង្សា : ២០-៣០

២៤-បាក់មួយភាគបី កណ្តាលឬខាងក្រោម នៃឆ្អឹងភ្លៅ ផ្ទៃឆ្អឹងមានគុណវិបត្តិ អក្សរវៀច
រួញខ្លីលើសពី ៤ ស.ម : ២០-៣០

២៥-បាក់មួយភាគបីខាងលើ ឬក៏ឆ្អឹងភ្លៅ ផ្ទៃឆ្អឹងមានគុណវិបត្តិ ចង្កៀចនៃអ័ក្ស
រឈឺធាច់នៅដំណើរ : ២៥-៣០

២៦-ចង្កេះរឹងក្រញូង់ គ្មានវៀចឆ្អឹងភ្លៅ : ២៥-៣០

២៧-ចង្កេះរឹងក្រញូង់វៀចឆ្អឹងភ្លៅ : ៣០-៣៥

២៨-សម្លាកមានគុណវិបត្តិនៃការរលាកនៅសន្លាក់ជង្គង់ "កន្ទាក់អាចម៏ " ឬនៅជង្គង់
លក្ខខណ្ឌបន្ថយចុះដែលចលនាបត់និងលាស្មងជើងតិចជាង ៥០ អង្សា : ៣០-៣៥

២៩-ជំងឺរលាកឆ្អឹង និងខួរឆ្អឹង "អូស្តេអូម្យេលីក " រន្ធធ្លាយឆ្អឹងច្រើនកន្លែង និងតោរដាន" រីងក្បាល : ២០-៥០

ប្រភេទទី ៤

ក-ក្បាល មុខ ក :

១ បាត់បង់មួយភាគនៃឆ្អឹងលលាដ៍ក្បាល ២ ៣ ម : ១៥ ២០

២ ការខ្វាក់ភ្នែកម្ខាង ម្ខាងទៀតធម្មតា : ២៥

៣-ឆ្អឹងថ្គាមខាងលើ :

-បាត់បង់ធ្មេញភាគច្រើន គ្មានលទ្ធភាពដាក់ធ្មេញបាន : ២០

-បាក់មិនពង្រឹងពង្រួមបាននៃឆ្អឹងថ្គាមខាងលើ សមត្ថភាពទំពារថយចុះ : ២០-២៥

-សន្លាក់ធ្មេញវៀចតិចតួច : ១៥-២០

-ធ្លុះធ្លាយក្រអូមមាត់ ធ្លាយពីម្ខាងទៅម្ខាងរវាងមាត់ច្រមុះ : ២០-៣០

៤-ឆ្អឹងថ្គាមខាងក្រោម :

-បាក់មិនពង្រឹងពង្រួមបាននៃមែក "ប្រង់ចិ " ទទឹង" ចាត់ថ្នាក់ទៅតាម
សមត្ថភាពទំពារ : ២០-២៥

៥-ភ្ជាត់ឆ្អឹងថ្គមសារដាន : ១០-២០

៦-កាត់អណ្តាតមួយភាគ រអាក់រអួលដល់ការនិយាយស្តី ការទំពារអាហារ
និងការលេបអាហារ : ១០-២០

៧-ធ្លង់ទាំងសងខាង កំរិតមធ្យម : ២០-២៥

៨-កាត់ច្រមុះចោល តម្រូវឱ្យផ្លាស់ប្តូរមុខវិជ្ជាជីវៈ ៖ ១០-២៥

៩-ជំងឺរលាកស៊ីនូសនៃថ្គាម "ស៊ីនូសអ៊ីត" ថ្ងាស អេថ្មូអ៊ីត ចាត់ថ្នាក់ទៅតាមការធ្ងន់ធ្ងរនៃជំងឺ
និងចំនួនស៊ីនូសដែលរងគ្រោះមានជំងឺ ៖ ១០-៣០

១០-វិបត្តិ ពាក្យសំដី និងវិបត្តិដកដង្ហើមមានប្រភេទពីរ :

-ខ្វិនឈឺវ៉ូរ៉េកូរេនតិ

-សម្ពាធនៅបំពង់សំលេង ដើមក

-ជំងឺរលាកសន្លាក់គ្រីកូ -អារីថេន័រអ៊ីដ :

.និយាយមិនឮ ៖ ២០-៣០

.រាក់ដង្ហក់មធ្យម ៖ ១៥-២០

១១-កំរើលប៉ះទង្គិចមកពីសន្ទុះខ្យល់ធាក់នៃការផ្ទុះ

-អាការៈរាគផ្ទាល់ខ្លួនជាប់បន្តពីការរញ្ជួយខួរ "សណ្ឋានស្រាល" ៖ ២០

-វិបត្តិនៃពាក្យសំដីនិងការិតស្តាប់សូរសំលេងអាគ្វីពេត្រចៀកធ្លាក់ចុះ ៖ ១១-២០

-ជំងឺប៉ាស៊ីដូវ៉ី "ពពក" កើតឡើងនៅរវាងខែដំបូងក្រោមការប៉ះទង្គិច ៖ ៥-២០

-ឈាមហៀរចេញផ្ទៃម "ទឹកនោមផ្អែម" ជាប់បន្តពីការប៉ះទង្គិចលលាដ៍ ឬការចុកទង្គិច ៖ ២៥

១២-ជំងឺប៉ារបួសផ្នែកទន់ "សាច់ដុំ" នៅស្មាជាមួយនឹងស្នាមដុំនៃសាច់ដុំក និងមុខ ៖ ១៥-២០

<u>ខ-ភ្នែក និងសរីរាង្គក្នុងភ្នែក</u> :

១-វះកាត់ក្លែបស្ងួត "ឡូបេកតូមី" ជាមួយនឹងសមត្ថភាពដកដង្ហើមថយចុះតិចតួច ៖ ១៥-២០

<u>គ-ពោះ និងសរីរាង្គក្នុងពោះ</u> :

១-ដំណ "កាត់ពភ្ជាប់ ក្រពះ ពោះវៀន" ៖ ១៥-២០

២-ស្ទះពោះវៀន វះកាត់ឡើងវិញ មកពីវិបត្តិនៃអន្តរាគមន៍វះកាត់ចាស់នៃពោះវៀន ៖ ១៥-២៥

៣-វះកាត់ពោះវៀនតូច "តិចជាងមួយម៉ែត្រ" ៖ ២០-២៥

៤-កាត់ថ្លើមចោលមួយភ្លែប ៖ ២០-២៥

៥-វះកាត់ផាស "អណ្តើក" អនៈហេមីមធ្យម ៖ ១៥-៣៥

<u>ឃ-ត្រគាក សរីរាង្គត្រគាក អង្គជាតិ</u> :

១-កាត់ពងស្វាសចោលទាំងពីរ លើបុរសអាយុលើសពី ៥០ ឆ្នាំ ៖ ១០-២០

២-វះកាត់ស្បូនចំពោះស្ត្រីអាយុលើសពី ៤៥ ឆ្នាំដែលមានកូន ៖ ២០-២៥

៣-សម្ពាកច្រើនអន្ទីនៃទ្វារមាស និងយោនី ៖ ១០-២៥

៤-កាត់សិដនចោលម្ខាងនៅស្ត្រី ឬក្មេងស្រី ៖ ១០-២០

៥-បាក់ឆ្អឹងគូថ ជាមួយនឹងវិបត្តិសាច់ដុំជើង និងសរ ៖ ២០-២៥

<u>ង-អវយវៈ</u> :

១-បាត់បង់មេដៃ និងឆ្អឹងបាតដៃ ៖ ១៨-២១

២-ចង្អុល និង ម្រាមដៃពីរទៀត ក្រៅពីមេដៃ ៖ ២០-២២

៣-បាត់បង់មេដៃ និងម្រាមដៃមួយទៀត ក្រៅពីចង្អុលដៃ ៖ ២០-២២

៤-បាត់បង់មេដៃ និងម្រាមដៃពីរទៀត ក្រៅពីចង្អុលដៃ ៖ ២០-២៥

៥-សម្ពាធធំនៃការលាកប្រអប់ដៃ, ម្រាមដៃរឹង និងក្រញ៉ាង ឬមិនលា បត់បាន :

-ម្រាមដៃទាំងប្រាំ ៖ ២៥-៣០

-រមេ និងចង្អុលដៃ	៖	២០-២៥
-មេ និងម្រាមដៃមួយទៀត	៖	១៥-២០
៦-សម្ពាធមានគុណវិបត្តិនៅកែងដៃ ដែលកំណត់ចលនាកំភួនដៃ :		
-លាតសន្ធឹងពី ១៨០ មក ១១០ អង្សា	៖	២០-២៥
-បំណត់ពី ១១០ មក ៧៥ អង្សា	៖	១៥-២០
-បំណត់ពី ៧៥ មក ៣៥ អង្សា	៖	១០-១៥
៧-សម្ពាធមានគុណវិបត្តិនៅក្លៀក ដែលកំណត់នៅចលនាស្មា :		
-ដើមដៃ កន្ទេកចេញពី ៤៥ អង្សា	៖	១០-២៥
-ដើមដៃកន្ទេកចេញពី ១០ អង្សា	៖	២៥-៣០
៨-សន្ទាក់ដៃរឹងក្រញង់ ជាមួយនឹងចលនាធម្មតានៃម្រាមដៃ :		
-ឥរិយាបថនៃមុខងារ "ធ្វើការងារ"	៖	១៥-២០
-ឥរិយាបថកោង	៖	២០-២៥
៩-បាក់ឆ្អឹងកំភួនដៃទាំងពីរ ផ្នែកឆ្អឹងមានគុណវិបត្តិ អ័ក្សវៀច រួញខ្លី	៖	១៥-២៥
១០-កែងដៃរឹងក្រញង់ជាមួយនឹងបំនត់ដើមកំភួនដៃពី ៦០ ទៅ ១១០ អង្សា	៖	១៥-២៥
១១-ស្មារឹងក្រញង់ ដើមដៃកន្ទេកចេញពី ៩០ អង្សា	៖	១០-២៥
១២-ខ្វិនណឺរ្វ រេឌីយ៉ូ នោកន្លែងកដៃ	៖	២០-២៥
១៣-ខ្វិនណឺរ្វ កូប៊ីតាល់	៖	១៥-២៥
១៤-ខ្វិន រ៉េភ្លាចនៅខាងក្រោមទ្រីសេបស៍	៖	២០-២៥
១៥-បាក់ឆ្អឹង... ផ្នែកឆ្អឹងមានគុណវិបត្តិរួមជាមួយនឹងសញ្ញា... [illegible]	៖	១៥-២៥
១៦-បាក់ឆ្អឹងស្មាបប្រចៀវ	៖	១០-៣០
១៧-បាត់បង់ម្រាមជើងប្រាំ	៖	៥-១០
១៨-បាត់បង់ឆ្អឹងអាំស្ត្រាគ្គាល	៖	២៥
១៩-បាត់បងឆ្អឹងកែងជើង	៖	២៥-៣០
២០-សន្ទាក់ឆ្អឹងកជើងរឹងក្រញង់	៖	១៥-២០
២១-បាត់បង់ភ្នែកគោលទាំងពីរ ស្មងវៀច	៖	១៥-២០
២២-បាក់ឆ្អឹងស្មងទាំងពីរ "ទីប្យា និងហ្វេរ៉ូណេ" ផ្នែកឆ្អឹងមានគុណវិបត្តិ ស្មងវៀច រួញខ្លីតិចជាង ៥ ស.ម	៖	១៥-២០
២៣-លេស្យុង ជង្គង់ ឥរិយាបថអនុគ្រោះដល់ស្មង "១៣៥-១៨០ អង្សា"	៖	១៥-២០
២៤-អង្គធាតុដទៃនៅក្នុងសន្ទាក់ជង្គង់	៖	១០-២៥
២៥-ជង្គង់រឹងក្រញង់ ឥរិយាបថស្តាំនៃស្មង "១៨០ អង្សា"	៖	១៥-២៥
២៦-សម្ពាធមានគុណវិបត្តិនៃការរលាកនៅសន្ទាក់ជង្គង់ "កន្ទាក់អាចមី" ឬនៅជង្គង់កំណត់ចលនាបត់ និងលាពី ៩០ - ១៣៤ អង្សា	៖	១០-៣០
២៧-ដំបៅស្មង សម្ពាធមានគុណវិបត្តិជាមួយនឹងការរួញខ្លីនៃសសៃកែង "តង់ដុងអាស៊ីល"	៖	១៥-២៥
២៨-បាក់មួយភាគបីខាងលើនៃឆ្អឹងភ្លៅ ឬក៏ឆ្អឹងភ្លៅ ផ្នែកឆ្អឹងមានវិបត្តិសាច់ដុំខាងក្រោមវៀចឈឺចាប់នៅដំណើរ	៖	២៥-៣០
២៩-ខ្វិនណឺរ្វស្យាទីគ	៖	២៥

៣០-ឈឺចាប់នៃណឺរ៉ូស្យាទីក ចាត់ថ្នាក់ទៅតាមកំរិតនៃការឈឺចាប់ និងកំរិតនៃការលំបាក លំបិននៅដំណើរ	៖	១០-២៥
៣១-ភ្ជាត់ឆ្អឹងចង្កេះ និង រឹងក្រញូង់	៖	២០-២៥
៣២-ជំងឺរលាកឆ្អឹង និងខ្នង ជាមួយនឹងរន្ធធ្លាយច្រើនអន្លើ និងសារជាតិ	៖	២០-៣០
៣៣-ស្ទិតសាច់ដុំ ឈឺចាប់ ចាំរើស៊ីអវៈយវៈមកពីការព្យាបាលដោយសេរ៉ូមអង់ទីតេតានិច	៖	២០
៣៤-អាណេវ្រីស្មអាវទែរ វ៉ែន នៃអវៈយវៈ ចាត់ថ្នាក់ទៅតាមវិប្បរិតនៃរបស់ឈាម និង វិបត្តិនៃមុខងារផ្លាស់ប្តូរកន្លែង	៖	៥-២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ២៧៥ ប.ក

ប្រកាស

ស្តីពីការបង្កើត ការិយាល័យរដ្ឋបាល និងសរុប ចំណុះនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ ០៩៥ ប្រ.ក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សំរេច

ប្រការ ១ : ត្រូវបង្កើតអោយមានការិយាល័យមួយឈ្មោះថា "ការិយាល័យរដ្ឋបាល និងសរុប "។

ប្រការ ២ : ការិយាល័យរដ្ឋបាល និងសរុប ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

ប្រការ ៣ : ការិយាល័យរដ្ឋបាល និងសរុប ដឹកនាំដោយប្រធានការិយាល័យមួយរូប អមដោយអនុប្រធានការិយាល័យពីររូប ជាជំនួយការ ។

ប្រការ ៤ : ការិយាល័យរដ្ឋបាល និងសរុប មានតួនាទី ភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ទទួលបន្ទុកលើការងារលិខិតចេញ ចូល លេខាហរី ទូរស័ព្ទ និងទូរសារ

- ធ្វើការបែងចែកលិខិតចូល ទៅអោយការិយាល័យពាក់ព័ន្ធចំណុះនាយកដ្ឋាន តាមចំណារ របស់ប្រធាននាយកដ្ឋាន ។
- ធ្វើការបែងចែក និងផ្ញើរចេញ នូវលិខិតស្នាមទាំងឡាយដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចុះហត្ថលេខា និងបោះត្រារួចស្រេចហើយ ។
- រៀបចំសំណុំលិខិតនានា ដាក់ជូនប្រធាននាយកដ្ឋានពិនិត្យ ។
- ទទួលខុសត្រូវលើការថែរក្សាច្បាប់ លិខិតបទដ្ឋានទាក់ទងការងារបុគ្គលិក និងតម្កល់ឯកសារ ។
- ចាត់ចែងសំអាត តុបតែង លំអ និងការងារពិធីការ របស់នាយកដ្ឋាន ។
- រៀបចំ គំរោងចំណាយថវិកា និងការផ្គត់ផ្គង់មធ្យោបាយសំភារៈរដ្ឋបាល សំដៅអោយការងារនៅនាយកដ្ឋាន ដំណើរការមាននិរន្តរភាព និងប្រសិទ្ធភាព ។
- ទទួលបើកប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ប្រេងឥន្ធនៈ ជូនមន្ត្រីរាជការនៅក្នុងនាយកដ្ឋាន ។
- ធ្វើរបាយការណ៍បូកសរុបការងារ ប្រចាំសប្តាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និង និង បូកសរុបទិសដៅការងារ របស់នាយកដ្ឋាន ។
- ពិនិត្យ បូកសរុប វិភាគ វាយតម្លៃ សន្និដ្ឋានលើរបាយការណ៍ពីគ្រប់ការិយាល័យ ចំណុះនាយកដ្ឋាន ជូនប្រធាននាយកដ្ឋាន ពិនិត្យ សំរេច ។
- ចូលរួមធ្វើកំណត់ហេតុក្នុងអង្គប្រជុំនានារបស់នាយកដ្ឋាន ។
- បំពេញការងារផ្សេងៗទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីប្រធាននាយកដ្ឋាន ។

ប្រការ ៥ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាល គ្រប់ខេត្ត ក្រុង ប្រធាននាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និង អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ. ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០២

សហរដ្ឋមន្ត្រី

ស ខេង

ចម្លងជូន

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
  (ដើម្បីជូនជ្រាប)
- *ដូចប្រការ ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*